ឧបសម្ព័ន្ធ ១

# របាយការណ៍បូកសរុប
# ប្រចាំឆ្នាំ២០២២







## អង្គការកែប្រែសហគមន៍

#០៩៩ ក្រុមទី១ ភូមិថ្នល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប

Facebookpage: CTO Cambodia-អង្គការកែប្រែសហគមន៍ Website: www.ctocambodia.org

**ប្រភពមូលនិធិ:** actionaid

មាតិការ

I. អំពីអង្គការកែប្រែសហគមន៍
II. ព័ត៌មានគម្រោង
III. ពិពណ៌នាការរីកចម្រើនរបស់គម្រោង
IV. របាយការណ៍ហិរញ្ញវត្ថុ
V. ផែនការទិសដៅការងារបន្ត

## I. អំពីអង្គការកែប្រែសហគមន៍

អង្គការកែប្រែសហគមន៍ Community Translation Organization, អក្សរកាត់ (CTO) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលត្រូវបានចុះបញ្ជីរនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា លេខ ១៩៩៣ សជណ ថ្ងៃទី៣០ ខែ មិថុនា ឆ្នាំ ២០០៩។ ស្នាក់ការកណ្តាលរបស់អង្គការមានទីតាំងស្ថិតនៅ ផ្ទះលេខ ០៩៩ ផ្លូវជាតិលេខ៦ ភូមិថ្នល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប និងស្នាក់ការសាខាទីតាំងស្ថិតនៅ ភូមិអូរក្រាំន់ សង្កាត់សំរោង ក្រុង សំរោង ខេត្តឧត្តរមានជ័យ។ ដែលជាទីតាំងយុទ្ធសាស្ត្រមួយដើម្បីសម្របសម្រួលប្រតិបត្តិការ ការងារចូលរួមកិច្ចការងារអភិវឌ្ឍន៍ សម្រាប់បណ្តាខេត្តភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជា ដូចជាខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពង់ធំ។

អង្គការកែប្រែសហគមន៍ ធ្វើការងារដើម្បីកសាងអំណាចមូលដ្ឋានគ្រឹះដល់សហគមន៍ ដែលអាស្រ័យផលនឹងរបរកសិកម្ម ដោយផ្តោតលើវិស័យកសិកម្ម គ្រប់គ្រងធនធានធម្មជាតិ ការកសាងសមត្ថភាពក្រុមអង្គការមហាជន ដែលមានដូចជា ក្រុមសន្សំប្រាក់ សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍ទេសចរធម្មជាតិ សហគមន៍ស្រះជម្រកត្រីមេពូជ ជម្រុញការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ការអប់រំកុមារនៅកម្រិតថ្នាក់មូលដ្ឋាន ការលើកំពស់សមភាពយែនឌ័រ សហគ្រិនភាពនារី ការអប់រំផ្សព្វផ្សាយដល់សហគមន៍ លើបញ្ហាបម្រែបម្រួល និងការបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះភ័យធម្មជាតិ ដើម្បីឆ្ពោះទៅរកការកសាងសមត្ថភាពសហគមន៍ ដែលអាចធន់ទ្រាំទៅនឹងបញ្ហាសង្គម និងសេដ្ឋកិច្ច។

អង្គការកែប្រែសហគមន៍ គឺជាផ្នែកមួយនៃកម្មវិធីរបស់អង្គការ Human Translation ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយមានមូលដ្ឋាននៅសហរដ្ឋអាមេរិក (គេហទំព័រwww.humantranslation.org)។ ក្នុងឆ្នាំ២០០៩ តាមរយៈការធ្វើកំនែទម្រង់ អង្គការកែប្រែសហគមន៍ បានប្រែក្លាយមកជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យក្នុងស្រុកមួយ ដែលបានចុះបញ្ជីទទួលស្គាល់ស្របច្បាប់ជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅក្រសួងមហាផ្ទៃ។

- បាវចនា ៖ ប្រែក្លាយចំណេះដឹងទៅជាសកម្មភាពអភិវឌ្ឍន៍។
- ទស្សនវិស័យ ៖ ប្រជាជនអាចធ្វើកិច្ចការដើម្បីកែលំអរជីវភាព និងសេដ្ឋកិច្ចបានប្រសើរឡើង នៅពេលដែលពួកគាត់ទទួលបាននូវសម្ភារៈ ចំណេះដឹង ជំនាញ និង ធនធានសមស្រប។
- បេសកកម្ម ៖ ចូលរួមជាមួយសហគមន៍ ក្នុងការកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការពង្រឹងភាពអង់អាចរបស់សហគមន៍ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធរូបវន្តកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ អេកូទេសចរណ៍ និងធ្វើអោយប្រសើរឡើងនូវការចិញ្ចឹមជីវិតដោយភាពថ្លៃថ្នូរ និងមានការការគោរពសិទ្ធិ សេរីភាពពេញលេញ។

### ក.ក្រុមប្រឹក្សាភិបាលរបស់អង្គការ

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន |
|---|---|---|
| Kat Bun Heng | ស្ថាបនិក<br>ប្រធានក្រុមប្រឹក្សាភិបាល | សាលាកំរើក ក្រុងសៀមរាប<br>E-mail: kat.bunheng@gmail.com |
| Tobias Rose-Stockwell | ស្ថាបនិក<br>សមាជិកក្រុមប្រឹក្សាភិបាល | California, USA<br>E-mail: tobias@humantranslaionn.org |
| Jon Morgan | សមាជិកក្រុមប្រឹក្សាភិបាល /ប្រធាន<br>LAKECLINIC.org | ស្វាយដង្គុំ ក្រុងសៀមរាប<br>E-mail: jmorgan@lakeclinic.org |
| Kristen Davies | សមាជិកក្រុមប្រឹក្សាភិបាល<br>ទីប្រឹក្សាឯករាជ្យ | សាលាកំរើក ក្រុងសៀមរាប<br>E-mail : kdavies025@gmail.com |

### ខ.បុគ្គលិកលេខាធិការដ្ឋាន

| ល.រ | នាម និងគោត្តនាម | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន | ទំនាក់ទំនង |
|---|---|---|---|---|
| ១ | លោក ឃិញ យ៉ា | នាយកប្រត្តិបត្តិ(ពេញម៉ោង) | សៀមរាប | ០១២៧០៧៤៧៤ |
| ២ | លោកស្រី សៀង សុធារី | ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ(ពេញម៉ោង) | សៀមរាប | ០១២៤៥១៨៧៧ |
| ៣ | លោក ម៉យ រ៉ាមន | មន្ត្រីកម្មវិធី(ក្រៅម៉ោង) | សៀមរាប | ០៩២៧២៨១៩២ |
| ៤ | លោកស្រី ទេព សាម៉េត | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩២៥០២៦២០ |
| ៥ | កញ្ញា ព្រុំ សុទ្ធាលីស៊ី | មន្ត្រីជំនួយការកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩៣២៤០១០១០ |
| ៦ | លោកស្រី យ៉ាន់ ម៉ូរជី | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៣១៧៩៩៧ |
| ៧ | កញ្ញា សួន សោភា | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៨៨៩៩១៤០៥០ |
| ៨ | កញ្ញា ទីវ សាន្តេ | ជំនួយការរដ្ឋបាល(ក្រៅម៉ោង) | សៀមរាប | ០៩៧០១៣៧៣ |
| ៩ | Ms.Lola Bailly | អ្នកស្ម័គ្រចិត្ត | បារាំង | lola.bailly@hotail.fr |

## គ.វិស័យផ្តោត

| ប្រភេទនៃកម្មវិធី/គម្រោង/សកម្មភាព | ទីកន្លែង | រយៈពេល | ដៃគូគម្រោង | ប្រភពថវិកា / យន្ទិជ | ស្ថានភាព/បញ្ចប់/កំពង់បន្ត |
|---|---|---|---|---|---|
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំនិងយែនឌ័រ | សៀមរាប | ៣ឆ្នាំ | -ក្រុមប្រឹក្សឃុំ<br>-ការិយាល័យអប់រំស្រុក | Actionaid | បញ្ចប់ ០១មេសា២០១៦ |
| និយ័តកម្មព្រៃឈើ ទឹកស្អាតនិងអនាម័យ | ព្រះវិហារ | ៣ ឆ្នាំ | -សហគមន៍ព្រៃឈើ<br>-រដ្ឋបាលព្រៃឈើ<br>-មន្ទីរអភិវឌ្ឍន៍ជនបទ | OXFAM GB | បញ្ចប់ ០៨សីហា២០១៥ |
| អេកូទេសចរណ៍ គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាស ធាតុការចិញ្ចឹមជីវិត | សៀមរាប | ២ ឆ្នាំ | ក្រុមប្រឹក្សឃុំ | UNDP SGP | បញ្ចប់ ៣០ធ្នូ២០១៣ |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៨ឆ្នាំ | សហគមអភិវឌ្ឍកសិកម្ម | SIDA/ WEFFECT | បញ្ចប់ (កក្កដា២០២០) |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៥ ឆ្នាំ | មន្ទីរកសិកម្ម | AusAID | បញ្ចប់ ០៦កក្កដា២០១៤ |
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំ និងយែនឌ័រ គ្រប់គ្រងគ្រោះមហន្តរាយ | ឧត្តរមានជ័យ | ៨ឆ្នាំ | -បណ្តាញសហគន៍ព្រៃឈើ<br>-បណ្តាញគាំទ្រសហគមន៍ | Actionaid | បន្ត |
| គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាស ធាតុការចិញ្ចឹមជីវិត | សៀមរាប | ១.៨ ឆ្នាំ | ក្រុមប្រឹក្សឃុំ<br>ឧទ្យានជាតិ<br>រដ្ឋបាលស្រុក | UNDP SGP | បញ្ចប់ ២០១៨ |
| កសិកម្ម និងការចិញ្ចឹមជីវិត | សៀមរាប | ១ឆ្នាំ | សហគមន៍កសិកម្ម | DAP/DIFAT | បញ្ចប់ ២០១៨ |
| ជម្រុញសហគ្រិនវ័យក្មេង | សៀមរាប | ២ឆ្នាំ | ពាណិជ្ជកម្ម | PACT/WE Act | បញ្ចប់ ២០២២ |

## II. ព័ត៌មានគម្រោង

១.ខេត្តឧត្តរមានជ័យ មានគម្រោងមេ១ដែលប្រភពថវិកាមកពី Actionaid

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីសិទ្ធិមូលដ្ឋាន (LRP) |
| គោលដៅរួម | កសិករ និងកុមារក្រីក្រនៅក្នុងតំបន់គោលដៅរបស់គម្រោង នឹងទទួលបាននូវសន្តិសុខស្បៀង និងឱកាសទទួលបានការសិក្សាប្រសើរជាងមុន ដោយពួកគេមានលទ្ធភាព ទទួលបាននូវសិទ្ធិជាមូលដ្ឋាន ហើយអនុវត្តសិទ្ធិទាំងនោះតាមផ្លូវច្បាប់ ដើម្បីរស់នៅប្រកបដោយភាពថ្លៃថ្នូរនៅក្នុងសង្គម។ |
| តំបន់គោលដៅ | -ខេត្ត: ឧត្តរមានជ័យ<br>-ស្រុក: សំរោង បន្ទាយអំពិល ចុងកាល់ អន្លង់វែង<br>-ឃុំ: សំរោង បន្សាយរាក់ កូនក្រៀល គោកខ្ពស់ ពង្រ លំទង |
| ក្រុមគោលដៅ | សហគមន៍ព្រៃឈើ១១ បណ្តាញសហគមន៍ព្រៃឈើខេត្ត១ សាលាបឋមសិក្សា២៥ |
| អ្នកទទួលផលផ្ទាល់ | ១៨៦៣គ្រួសារ |
| អ្នកទទួលផលប្រយោល | ៩៣៣៨នាក់ ស្រី៤៧៥០នាក់ ក្នុងនោះកុមារសរុប៣២៦៨នាក់ |

## III. ពិពណ៌នាការរីកចម្រើនរបស់គម្រោង

### ១.ខេត្តសៀមរាប

ឆ្នាំ២០២២ គម្រោងដែលធ្លាប់មាននៅខេត្តសៀមរាបត្រូវបានចប់ ហើយកំពុងស្វែងរកប្រភពមូលនិធិថ្មី។

### ២.ខេត្តឧត្តរមានជ័យ

**គម្រោងកម្មវិធីសិទ្ធិនៅមូលដ្ឋាន(LRP)**

*សង្ខេបសមិទ្ធផលគម្រោង*

នៅចុងឆ្នាំ២០២២ ក្រោយពីធ្វើការបូកសរុបលទ្ធផលការងារ ហើយនិងធ្វើការវិភាគទិន្នន័យប្រចាំឆ្នាំ អង្គការកែប្រែសហគមន៍បានអនុវត្តសកម្មភាព និងសម្រេចបានលទ្ធផលសំខាន់ៗដូចខាងក្រោមៈ

**ផ្នែកអប់រំ និងគាំពារកុមារ**

គម្រោងបានចូលរួមលើកកម្ពស់ការយល់ដឹង អំពីចំណេះដឹងពាក់ព័ន្ធនឹងគោលនយោបាយកិច្ចការពារកុមារ គោលនយោបាយស្តីពី ការបៀតបៀន ការបំពាន ការរំលោភផ្លូវភេទលើស្ត្រីនិងកុមារ គោលនយោបាយអប់រំបំណិនជីវិត និងការអនុវត្តរបស់សិស្សានុសិស្ស គណៈកម្មការទ្រទ្រង់សាលា និងលោកគ្រូ-អ្នកគ្រូក្នុងសាលាគោលដៅចំនួន២៥ ដែលកុមារសរុបចំនួន១,២៥៧ មានកុមារី ៦៩១ នាក់ ក្នុងក្រុងសំរោង ស្រុកចុងកាល់ និងបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

សាលារៀនក្នុងគោលដៅគម្រោងចំនួន៥ បន្ថែមលើសាលា១៥ផ្សេងទៀតដែលធ្លាប់ទទួលបានការគាំទ្ររួចមកហើយ ដែលជាផ្នែកមួយនៃការគាំទ្រផែនការអភិវឌ្ឍសាលាបានដឹកនាំរៀបចំអនុវត្តកម្មវិធីបំណិនជីវិត ដោយជ្រើសយកប្រធានបទលើវិស័យកសិកម្ម។ ទី១ សាលាបឋមសិក្សាអំពិល និងសាលាបឋមសិក្សាបាក់នឹម ជ្រើសយកប្រធានបទការរៀបចំសួនដំណាំពូជចេកចម្រុះ ដោយធ្វើការប្រមូលពូជចេកចំនួន៥ប្រភេទចំនួន៥ទៅ១០ដើមក្នុង១មុខ យកមកធ្វើការបង្ហាត់បង្ហាញពីបច្ចេកទេសក្នុងការដាំ ដើម្បីធ្វើការរក្សាជាពូជគោល ទុកអោយសិស្សានុសិស្សបានស្គាល់និងដឹងពីប្រភេទពូជចេកនានា ដែលមានក្នុងសហគមន៍របស់ពួកគាត់ និងដឹងលក្ខណៈខុសប្លែកគ្នារបស់វា។ ទី២ សាលាបឋមសិក្សាពង្រ សាលាបឋមសិក្សាបន្ទាយជ័រ និងសាលាបឋមសិក្សារំដួលវាសនាជ្រើសរើសយកការរៀបចំដំណាំឬស្សីផ្អែមសរុបចំនួន៦០៣ដើម ព្រោះជាពូជឬស្សីដែលមិនដែលធ្លាប់មានក្នុងសហគមន៍ ហើយជាពូជដែលផ្តល់ផលប្រយោជន៍ និងធន់នឹងអាកាសធាតុ សមសម្របនឹងលក្ខខ័ណ្ឌភូមិសាស្ត្រដែលក្តៅហួតហែងក្នុងរដូវប្រាំង ដោយ

ការដាំប្រើប្រាស់ជាពហុប្រយោជន៍ ដើម្បីជាម្លប់ ជាពូជសម្រាប់ចែកសហគមន៍បន្ត ជារបងការពារសំគាល់ព្រំប្រទល់បរិវេណសាលា និងដើម្បីបានទំពាំងសម្រាប់ធ្វើជាបន្លែ ហើយនឹងដើមឬស្សីសម្រាប់ធ្វើសំណង់ ឬសម្ភារះប្រើប្រាស់ផ្សេងៗ។

ក្រោយមានការសម្របសម្រួលតាមរយះគម្រោង ហើយនឹងកិច្ចសហការជាមួយមន្ទីរអប់រំយុវជននិងកីឡា ក្នុងការចុះជម្រុញ និងតាមដានការអនុវត្តកម្មវិធីបំណិនជីវិត ត្រួតពិនិត្យតាមដានការអនុវត្តន៍សកម្មភាពបំណិនជីវិត និងផែនការអភិវឌ្ឍសាលារៀន របស់គណៈកម្មការទ្រទ្រង់សាលា ដោយចុះសម្របសម្រួល និងតាមដានសកម្មភាពបំណិនជីវិត៥សាលារៀនចំនួន១៥ដង និងចុះសម្របសម្រួល តាមដានការប្រើប្រាស់ឡដុតសម្រាមទាំង១០សាលាបានចំនួន៣៥ដង។ តាមសាលាគោលដៅគម្រោង យើងទទួលបានជោគជ័យដោយសាលាគោលដៅគម្រោងទាំង២៥ បានសម្រេចដាក់បញ្ចូលម៉ោងសិក្សាកម្មវិធីបំណិនជីវិត ទៅក្នុងកាលវិភាគនៃកម្មវិធីសិក្សាតាមសាលា។ សម្រាប់ជំហ៊ានបន្ត យើងនឹងជួយជម្រុញអោយសាលា ដោះស្រាយបញ្ហាប្រឈមដែលសេសសល់ដើម្បីធានាអោយការអនុវត្តកម្មវិធីបំណិនជីវិត ដែលមានតាមសាលាអាចអនុវត្តបានស្របតាមគោលការណ៍ និងខ្លឹមសារដែលកំណត់ដោយក្រសួងអប់រំ។

ក្នុងពេលសម្រាកវិស្សមកាលនេះ គម្រោងបានសម្របសម្រួលដល់សាលា២ អោយជួយដល់សិស្សដែលរៀនខ្សោយទទួលបានការបង្វឹកបំប៉នដល់កុមារសរុបចំនួន៥០នាក់ មកពីគ្រប់កម្រិត ដោយជ្រើសយកទីតាំងក្លឹបកុមារជាកន្លែងសម្រាប់អោយសិស្សជួបជុំគ្នា រាល់ថ្ងៃដើម្បីធ្វើការស្វ័យសិក្សា និងទទួលការបង្វឹកពីគ្រូបង្គោលមួយរូបដែលទទួលខុស ត្រូវបង្វឹកបំប៉នដល់សិស្សទាំងនោះដើម្បីអោយគាត់មានលទ្ធភាពអាចរៀនទាន់សិស្សដែលខ្លាំងៗ ហើយកាត់បន្ថយអាត្រារៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សារបស់កុមារដោយសាររៀនខ្សោយ។

បុគ្គលិកគម្រោងបានចុះសម្របសម្រួលនិងតាមដានក្លិបកុមារទាំង១០ ព្រមទាំងពិនិត្យស្ថានភាពអាគារក្លិបកុមារទាំង២ សរុបចំនួន២៥ដង ដើម្បីជម្រុញការថែទាំងនិងការប្រើប្រាស់អោយបានយូរអង្វែង ព្រមទាំងតាមដានពង្រឹងការអនុវត្តកម្មវិធីស្វ័យសិក្សា ដល់កុមារចំនួន២ក្លឹបឡើងវិញ បន្ទាប់ពីផ្អាកអស់រយះពេលជាយូរដោយសារបញ្ហារាតត្បាតកូវីដ១៩ (សិស្សពូកែបង្រៀនសិស្សខ្សោយ)។ ប្រមូលសារកុមារបាន៣៥ភូមិ ក្នុង២ឃុំ ៣សង្កាត់ ២ស្រុក ១ក្រុង លទ្ធផលទទួលបានសារកុមារបានចំនួន១២៥៩សារ ដែលក្នុងនោះកុមារចាស់បាន៩៨៩នាក់ ហើយកុមារជ្រើសរើសថ្មីបាន២៧០នាក់ និងបានផ្ញើរសារកុមារទៅអាក់សិនអេដស្ទើរទាំងអស់ ដោយនៅខ្វះខាតតិចតួចនឹងបំពេញបន្ថែម។

**ផ្នែកគ្រប់គ្រងធនធានធម្មជាតិ ( សហគមន៍ព្រៃឈើ)៖**

គម្រោងបានជួយពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច ដល់ប្រជាសហគមន៍ព្រៃឈើ ជាពិសេសស្ត្រី និងយុវតី ១៨៥នាក់ នៅក្នុងក្រុងសំរោង ស្រុកបន្ទាយអំពិល និងស្រុកចុងកាល់ បានទទួលការគាំទ្រលើកកំពស់សិទ្ធិជាមូលដ្ឋានរបស់ពួកគាត់យ៉ាងសកម្ម ក្នុងការចូលរួមក្នុងការគ្រប់គ្រងធនធានព្រៃសហគមន៍ ដើម្បីទាញយកប្រយោជន៍ពីផលនិងអនុផលព្រៃឈើ ក្នុងចំណោមសមាជិកសរុប ៤២៦នាក់របស់សហគមន៍ព្រៃឈើចំនួន៣ (រំដួលវាសនា ភ្នំដងរែកសម្រែកព្រៃស្រស់ និងរតនរុក្ខា) និងបណ្តាញសហគមន៍ថ្នាក់ខេត្តចំនួន១២នាក់។ម្យ៉ាងវិញទៀត គម្រោងបានជួយអោយពួកគាត់បានយល់កាន់តែច្បាស់អំពីតួនាទី និងការទួលខុសត្រូវ របស់សហគមន៍ព្រៃឈើ អត្ថប្រយោជន៍នៃការបង្កើតសហគមន៍ព្រៃឈើ ច្បាប់បទដ្ឋានគតិយុត្តិពាក់ព័ន្ធ មានចំណេះដឹងកាន់តែប្រសើរដោយការប្រើប្រាស់ បច្ចេកវិទ្យាថ្មី ដើម្បីដឹងពីព្រំប្រទល់ព្រៃសហគមន៍ ព្រមទាំងកាន់តែផុសផុលចូលរួមក្នុងសកម្មភាពការពារ ថែរក្សា និងគ្រប់គ្រងព្រៃសហគមន៍របស់ពួកគាត់។

គម្រោងបានគាំទ្រសំណើរនៃការប្រជុំប្រចាំខែ ប្រចាំត្រីមាស របស់គណៈកម្មការសហគមន៍ទាំង៣ បានចំនួនសរុប១៨ដង ដើម្បី ពិភាក្សាដោះស្រាយបញ្ហា ពង្រឹងការគ្រប់គ្រង និងរៀបចំផែនការអនុវត្តសកម្មភាពតាមសហគមន៍។ គាំទ្រការប្រជុំប្រចាំត្រីមាស របស់បណ្តាញសហគមន៍ព្រៃឈើថ្នាក់ខេត្តបានចំនួន២លើក ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ពួកគាត់ ក៏ដូចជាការពិភាក្សាដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានក្នុងបណ្តាញ និង សហគមន៍ដែលជាសមាជិកបណ្តាញ ហើយនឹងលើកទិសដៅផែនការត្រូវអនុវត្តបន្ត។ បន្ទាប់មកនៅចុងឆ្នាំយើងបានប្រជុំធ្វើបច្ចុប្បន្នភាព តាមសហគមន៍បានចំនួន១១សហគមន៍ ដើម្បីតាមដានវឌ្ឍនភាព និងស្ថានភាពទូទៅរបស់សហគមន៍អស់ធៀបនឹងស្ថានភាពដែលបានបច្ចុប្បន្នភាពកាលពីលើកចុងក្រោយ។

គម្រោងបន្តជម្រុញ និងគាំទ្រការអភិវឌ្ឍការរៀបចំតំបន់ចរណ៍ធម្មជាតិតាក្របីព្រៃស្រស់ ផ្អែកទៅតាមផែនការមេដែលបានគ្រោងជាមួយសហគមន៍ ដោយបានចូលរួមនិងគាំទ្រក្នុងការបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិ ប្រជុំធ្វើផែនការអភិវឌ្ឍន៍តំបន់ចរណ៍ធម្មជាតិ និងពិភាក្សាសិក្សាពីគម្រោងសាងសង់ជណ្តើរឡើងភ្នំប្រាសាទតាក្របី។ គាំទ្រសម្ភារៈសម្រាប់អភិវឌ្ឍអេកូទេសចរមានកន្ទេលស្នោរ៥ ខ្នើយ១៥ ភួយ១០បន្ថែម សម្រាប់ចាប់ផ្តើមដំណើរការផ្តល់សេវាជួលតង់ស្នាក់នៅ ហើយនឹងជួយសម្របសម្រួលក្នុងការរៀបចំសំណើរគម្រោង និងយុទ្ធសាស្ត្រដើម្បីជួយអោយសហគមន៍ អាចគៀរគរធនធានពីប្រភពផ្សេង ដើម្បីមកបំពេញតម្រូវការជាក់ស្តែងដែលមិនត្រូវពឹងផ្អែកតែពីមួយប្រភព សំដៅអោយសម្រេចផែនការទាំងអស់បានលឿនតាមផែនការដែលគ្រោងទុក។

គាំទ្រលើផែនការសហគមន៍រតនរុក្ខា រំដួលវាសនា សហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងសហគមន៍ផ្សេងទៀតដែលចំណុះអោយបណ្តាញសហគមន៍ព្រៃឈើ ចុះល្បាតព្រៃបានសរុបចំនួន១៥ដង ដើម្បីត្រួតពិនិត្យស្ថានភាពព្រៃ ព្រំប្រទល់ តាមដានទប់ស្កាត់បទល្មើស ប្រមូលភ័ស្តុងដើម្បីកសាងពាក្យបណ្តឹងទៅកាន់អាជ្ញាធរមានសមត្ថកិច្ច។

**ផ្នែកកម្មវិធីបំណិនជីវិតតាមសាលា**

គោលបំណងទី៣៖ ៣.២ លើកកម្ពស់ការយល់ដឹង និងការអនុវត្តរបស់សិស្សានុសិស្ស គណៈកម្មការទ្រទ្រង់សាលា និងលោកគ្រូ-អ្នកគ្រូក្នុងសាលាគោលដៅចំនួន២៥ ដែលកុមារសរុបចំនួន១,២៥៧ មានកុមារី៦៨១នាក់ ក្នុងក្រុងសំរោង ស្រុកចុងកាល់ និងបន្ទាយអំពិល ខេត្តឧត្តរមានជ័យ លើមុខវិជ្ជាបំណិនជីវិតក្នុងថ្នាក់រៀន។

លទ្ធផលទី ១.១៖ ៣.២. សាលាចំនួន២៥ បានបញ្ចូលមុខវិជ្ជាបំណិនជីវិត្ត ទៅក្នុងកម្មវិធីសិក្សា ដោយមានម៉ោងសិក្សាអំពីមេរៀនបំណិនជីវិតច្បាស់លាស់ ព្រមទាំងមានការជំរុញការអនុវត្តកម្មវិធីបំណិនជីវិតតាមសាលាទាំងនោះបានយ៉ាងល្អប្រសើរ។

| សុច្ចនករ | ផែនការ១ឆ្នាំ | លទ្ធផល១ឆ្នាំ | ពន្យល់ពីគម្លាត |
|---|---|---|---|
| 3.2.2 គាំទ្រសាលាគោលដៅ០៥ផែនការអភិវឌ្ឍន៍សាលារៀន និងសកម្មភាពបំណិនជីវិត | -គាំទ្រផែនការអភិវឌ្ឍសាលា ៥សាលា<br>-ដាក់បញ្ចូលមុខវិជ្ជាបំនិនជីវិតក្នុងកម្មវិធីសិក្សា ២៥សាលា | • ៥សាលា<br>• ២៥សាលា | -បានឆ្លើយតបនឹងគាំទ្រសំណើរទាំង៥សាលាហើយសាលានីមួយៗ បានអនុវត្តបង្ហាញដល់សិស្សតាមផែនការដែលគ្រោង<br>-យើងបានបំផុស និងជម្រុញតាមសាលាអោយ ដាក់បញ្ចូលមុខវិជ្ជាបំណិនជីវិតតាំងពីឆ្នាំ២០២០។ ឆ្នាំ២០២២នេះ សាលាទាំង២៥ សម្រេចព្រមដាក់មុខវិជ្ជានេះក្នុងកម្មវិធីសិក្សាហើយ |
| 3.2.3 ត្រួតពិនិត្យតាមដានការអនុវត្តន៍សកម្មភាពបំ | ២៥សាលា | ២៥សាលា | សាលាដែលត្រូវលើកគម្រោងផែនការអភិវឌ្ឍសាលាមានតែ៥ទេក្នុងឆ្នាំ២០២២ ប៉ុន្តែយើងត្រូវចុះតាមដាន និងពិនិត្យសាលាទាំង២៥ |

| | | | |
|---|---|---|---|
| ណិនជីវិត និងផែនការអភិវឌ្ឍសាលារៀនរបស់គណៈកម្មការទ្រទ្រង់សាលា | | | ដែលទទួលការគាំទ្រមុនលើផែនការអភិវឌ្ឍសាលា និងការអនុវត្តកម្មវិធីបំណិនជីវិតតាមសាលានីមួយៗ។ |
| 3.2.4 ការអនុវត្តកម្មវិធីសិស្សល្អដល់កុមារ ចំនួន ២ក្លឹប (សិស្សពូកែបង្រៀនសិស្សខ្សោយ) | ២ក្លឹប | ២ក្លឹប | ក្នុងថ្ងៃសម្រាកវ៉ាកងក្រុមការងារគម្រោងបានសម្របសម្រួលជាមួយនាយកសាលាចំនួន២ដើម្បីជ្រើសរើសសិស្សដែលរៀនខ្សោយក្នុងសាលាទាំងអស់ដើម្បីយកមកបំប៉ន និងធ្វើការស្វ័យសិក្សានៅអាគារក្លឹបកុមារដើម្បីអោយពួកគាត់អាចរៀនទាន់គេដែលមានចំនួនសរុប៣៥នាក់ |

*បរិយាយលំអិតពីលទ្ធផលសម្រេចបានជាព័ត៌មានបែបគុណភាព និងបរិមាណទីនេះ៖*

**3.2.2 គាំទ្រសាលាគោលដៅ០៥ផែនការអភិវឌ្ឍន៍សាលារៀន និងសកម្មភាពបំណិនជីវិត**

បន្ទាប់ពីធ្វើការសម្របសម្រួលតាមសាលាទាំង៥ អំពីសកម្មភាពបំណិនជីវិត ដែលនឹងលើកក្នុងផែនការអភិវឌ្ឍសាលាសម្រាប់ឆ្នាំ២០២២នេះ គម្រោងបានអនុម័តសំណើរថវិកា ដើម្បីចាត់ចែងរៀបសកម្មភាពបំណិនជីវិត ទៅដល់សាលារៀនចំនួន៥បន្ថែមលើសាលាដែលទទួលបានការគាំទ្រមុនៗ។ សាលារៀនភាគច្រើនដោយនៅជនបទដាច់ស្រាយាល មានដីនិងទីធ្លាធំទូលាយហើយមិនសូវមានរបងការពារបរិវេណសាលា ដូច្នេះហើយឆ្លងការពិគ្រោះយោបល់ រៀបផែនការគម្រោងកម្មវិធីបំណិនជីវិតតាមសាលា បានសម្រេចជ្រើសរើសយកប្រធានបទផ្នែកកសិកម្ម ដោយចាប់អារម្មណ៍ជ្រើសយកប្រភេទពូជដំណាំឬស្សីផ្អែម ដើម្បីដាំបង្ហាញដល់សិស្សពីបច្ចេកទេស ព្រមទាំងប្រែក្លាយដំណាំទៅជារបងព័ទ្ធកំណត់ព្រំប្រទល់ការពារសាលារៀន ក៏ដូចជាម្លប់សម្រាប់សិស្សជ្រកថ្ងៃ រក្សាលំនឹងអាកាសធាតុនៅរដូវក្តៅហួតហែង ទុកពូជឬស្សីដើម្បីចែកបន្តទៅសហគមន៍ ព្រមទាំងយកផលទំពាំងធ្វើបន្លែ និងឬស្សីធ្វើឧបករណ៍ប្រើប្រាស់ផ្សេងៗ។ បន្ទាប់មកទៀតមានសាលារៀន២កន្លែងបានជ្រើសរើសពូជដំណាំចេក ដោយការប្រមូលប្រភេទពូជដំណាំចេកដែលមានក្នុងសហគមន៍ ប្រមូលផ្តុំមកដាំក្នុងច្បារសាលារៀនក្នុងគោលបំណងអភិរក្សពូជចេកក្នុងសហគមន៍ផង និងបង្ហាញអោយសិស្សបានស្គាល់ពីប្រភេទអំបូរចេកដែលខុសគ្នាៗ ព្រមទាំងបច្ចេកទេសក្នុងការដាំចេកផងដែរ។ ស្ថានភាពដំណាំឬស្សីឃើញថាមានការលូតលាស់ល្អ ដែលមានការខូចខាតប្រហែល១៨% យើងនឹងបន្តធ្វើការជាមួយគណៈគ្រប់គ្រងសាលាដើម្បីជម្រុញការថែទាំអោយបានហ្មត់ចត់ សំដៅអោយមានការដុះលូតលាត់ហុចផលតាមផែនការដែលបានគ្រោងទុក។ អ្នកទទួលផលដែលបានចូលរួមក្នុងសកម្មភាពនេះសរុបចំនួន៥៤០នាក់ស្រី៣៩៦នាក់ ដែលក្នុងនោះជាកុមារ៨០%នៃចំនួនសរុប។

សាលារៀនទាំង២៥បានសម្រេចដាក់បញ្ចូលមុខវិជ្ជាបំណិនជីវិតក្នុងកាលវិភាគកម្មវិធីសិក្សាតាមផែនការដែលគម្រោងបានខិតខំជម្រុញរបស់គម្រោង ហើយទន្ទឹមនឹងនោះតាមសាលាគោលដៅបានបន្តប្រើប្រាស់ឡដុតសម្រាមដែលគម្រោងបានគាំទ្រសាងសង់ក្នុងការ ចូលរួមកែលំអរបរិស្ថានអនាម័យតាមសាលាប្រកបដោយផ្លែផ្កា។

**3.2.3 ត្រួតពិនិត្យតាមដានការអនុវត្តន៍សកម្មភាពបំណិនជីវិត និងផែនការអភិវឌ្ឍសាលារៀនរបស់គណៈកម្មការទ្រទ្រង់សាលា។**

បុគ្គលិកគម្រោង បានបន្តចុះសម្របសម្រួលជាមួយគណៈគ្រប់គ្រងសាលាចំនួន៥ ដែលមិនធ្លាប់ទទួលបានការគាំទ្រលើផែនការអភិវឌ្ឍសាលា មាន សាលាបឋមសិក្សាអំពិល សាលាបឋមសិក្សាពង្រ សាលាបឋមសិក្សាបន្ទាយជ័រ សាលាបឋមសិក្សាវាំងលវាសនា និងសាលាបឋមសិក្សាកូនដំរី។ បន្ថែមលើសហ្នឹងបុគ្គលិកគម្រោងបានបន្តចុះទៅសាលារៀនទាំង២០ផ្សេងទៀតដែលធ្លាប់ទទួលបានការគាំទ្រផែនការអភិវឌ្ឍសាលា ដើម្បីត្រួតពិនិត្យតាមដានពីស្ថានភាពវឌ្ឍនភាពរបស់សាលាក្រោយពេលទទួលបានការគាំទ្រផែនការអភិវឌ្ឍសាលា និងផ្តល់អនុសាសន៍កែលំអរនូវចំណុចខ្វះខាតដែលមាន ជុំវិញការអនុវត្តសកម្មភាពផែនការអភិវឌ្ឍសាលាដែលបានគាំទ្រដោយគម្រោង។ ក្រោយមានការជួបពិភាក្សាពិគ្រោះយោបល់ និងសម្របសម្រួលទៅលើផែនការយើងបានគាំទ្រទៅសាលាចំនួន៥ដើម្បីយកថវិកា គម្រោងទៅចាត់ចែងអនុវត្តផែនការអភិវឌ្ឍសាលាដោយផ្តោតលើការរៀបចំសួន

បំណិនជីវិតតាមសាលា មានសាលាចំនួន៣បានជ្រើសរើសយកពូជដំណាំឬស្សីផ្អែមទៅដាំ ដើម្បីបង្ហាញដល់សិស្សជាការរក្សាទុកពូជសម្រាប់ចែកដល់ស ហគមន៍នៅក្រោយ ព្រមទាំងប្រើប្រាស់ដំណាំឬស្សីជារបងការពារ និងកំណត់ព្រំប្រទល់បរិវេណសាលាហើយមានសា លា២បានលើកផែនការរៀបចំសួនដំណាំពូជចេកចម្រុះចំនួន៥មុខជាមួយឬស្សីផ្អែម ដើម្បីរក្សាពូជចេកដែលមានក្នុងសហគមន៍ប្រមូលផ្តុំទុក១កន្លែងសម្រាប់ងាយស្រួលអោយសិស្សានុសិស្សបានរៀនសូត្រពីប្រភេទពូជដំណាំចេកផ្សេងៗគ្នាដែលមាននៅក្នុងសហគមន៍របស់ពួកគេ ព្រោះកន្លងមកប្រជាជនមានពូជចេកផ្សេងៗគ្នា ដែលធ្វើអោយសិស្សអាចមិនដឹងពីប្រភេទពូជចេកដែលមានក្នុងសហគមន៍របស់ពួកគេមានប៉ុន្មានប្រភេទបាន។ បន្ទាប់មកបុគ្គលឹកគម្រោងបានសហការជាមួយមន្ទីរអប់រំខេត្តចុះធ្វើការត្រួតពិនិត្យតាមដានសាលារៀនគោលដៅគម្រោងទាំងអស់ដើម្បី ធ្វើការផ្តល់ការប្រឹក្សាយោបល់ និងមតិយោបល់ចូលរួមទៅលើការអនុវត្តកម្មវិធីបំណិនជីវិត ការប្រើប្រាស់ឡដុតសម្រាម និងសួនបំណិនជីវិតដែលគម្រោងបានគាំទ្រសំដៅស្វែងរកបញ្ហាខ្វះចន្លោះដើម្បីកែលំអរ និងជម្រុញអ្វីដែលធ្វើបានល្អប្រសើរហើយអោយកាន់តែជោគជ័យបន្ថែមទៀត។

**3.2.4 ការអនុវត្តកម្មវិធីសិស្សល្អដល់កុមារ ចំនួន ២ក្លឹប (សិស្សពូកែបង្រៀនសិស្សខ្សោយ)**

បុគ្គលិកគម្រោងបានចុះតាមដាន និងជម្រុញក្លឹបកុមារទាំង១០បានចំនួន២៥ដង។ ក្រោយពីការចុះត្រួតពិនិត្យក្លឹបនៅតាមសាលាចំនួន៥បានផ្អាកសកម្មភាព ព្រោះដោយសារបញ្ហារាតត្បាតកូវីដ១៩ ហើយម្យ៉ាងទៀតដោយគម្រោងបានកាត់ផែនការនេះចេញតាំងពីឆ្នាំ២០២០ ហើយស្របពេលសិស្សដែលចងក្រងក្លឹបបាន ឡើងថ្នាក់ហើយបែកខ្ញែកគ្នាផ្សេងៗ ស្របពេលគណគ្រប់គ្រងសាលាមមាញឹកលើសកម្មភាពបើកដំណើរការសាលាឡើងវិញ ក្នុងការជម្រុញសិស្សអោយចូលរៀន ក៏ដូចជាពង្រឹងកម្មវិធីសិក្សាគោលស្របតាមបរិបទដែលដែលសាលា ចាប់បើកដំណើរការឡើងវិញខុសពេលវេលា ក្នុងកម្មវិធីសិក្សាដែលធ្លាប់មាន។ អាគារក្លឹបកុមារដែលគម្រោងគាំទ្រការសាងសង់នៅស្ថានភាពល្អប្រសើរដដែលទាំង២ ប៉ុន្តែដំណើរការប្រើប្រាស់សកម្មភាពរបស់កុមារក្នុងក្លឹបមិនទាន់រៀបរយឡើងវិញដូចប្រក្រតីទេ ព្រោះត្រូវផ្តោតលើការសិក្សាកម្មវិធីសិក្សាគោល ហើយលក្ខខ័ណ្ឌមិនទាន់សមស្របក្នុងពេលដែលសាលាទើបបើកដំណើរការឡើង វិញក្រោយពេលធូរស្រាលកូវិឌ១៩ថ្មីៗ។ យ៉ាងណាក៏បុគ្គលិកគម្រោងបានពិភាក្សាជាមួយគណកម្មការគ្រប់គ្រងក្លឹប អោយបន្តយកចិត្តទុកដាក់ជួយថែរក្សាក្លឹបនិងសម្ភារះបរិក្ខាដែលមាននៅក្នុងក្លឹប កុំអោយមានការបោះបង់ចោលមិនមានអ្នកទទួលខុសត្រូវ ហើយនៅពេលដែលសិស្សរៀបរយនៅតាមសាលាលើកម្មវិធីសិក្សាដែលដាក់អោយអនុវត្តក្រោយកូវីដ១៩នេះ យើងនឹងចាប់ផ្តើមចលនាអោយកុមារតាមក្លឹប មកប្រើប្រាស់ជួបជុំគ្នាធ្វើសកម្មភាពដូចធ្លាប់មានកន្លង។ ក្នុងពេលសម្រាកវ៉ាកងបុគ្គលិកគម្រោងបានសម្របសម្រួលជាមួយគណះគ្រប់គ្រងសាលាចំនួន២អោយប្រមូលសិស្សដែលរៀនខ្សោយទាំងអស់អោយមកបំប៉នក្នុងក្លឹបកុមារទាំង២ មានសិស្សមកពីសាលាបឋមសិក្សាឈើស្លាប់ និងសាលាបឋមសិក្សាពោធិវង្ស ដែលមានសិស្សសរុប៤៥នាក់បានចូលរួមសកម្មភាពរៀនបំប៉ន និងធ្វើការស្វ័យសិក្សាដើម្បីនៅពេលចូលកងវិញ អាចរៀនទាន់គេហើយកាត់បន្ថយអាត្រាសិស្សដែលធ្លាក់មិនអាចឡើងថ្នាក់បានច្រើន។ ទន្ទឹមនឹងនោះដែរថវិកាគាំទ្រក្លឹបនេះយើងក៏បានចាត់ចែង ដើម្បីទិញអំពូលភ្លើងសូឡាបំពាក់តាមក្លឹបទាំង២ និងបំពាក់តាមក្លោងទ្វារសាលាចំនួន៦ថែមទៀត ដើម្បីអោយសហគមន៍អាចប្រើប្រាស់ក្លឹបនៅពេលល្ងាចបន្ថែម ព្រមទាំងបង្កើនសោភ័ណ្ឌភាពសន្តិសុខសុវត្ថិភាពនៅពេលយប់ ក៏ដូចជាការលើកកំពស់ការប្រើប្រាស់ថាមពលព្រះអាទិត្យ និងណែនាំអោយកុមារបានស្គាល់ដឹងពីបច្ចេកវិទ្យា ដែលបង្កើតបរិក្ខាប្រើប្រាស់ដើរដោយថាមពលព្រះអាទិត្យដល់ប្អូនៗកុមារនឹងសហគមន៍។

| |
|---|
| គោលបំណងទី២៖ ៣.៣ ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ច ដល់ប្រជាសហគមន៍ព្រៃឈើ ជាតិ សេសស្ត្រី និងយុវតី នៅក្នុងក្រុងសំរោង និងស្រុកបន្ទាយអំពិល តាម រយៈការគាំទ្រសិទ្ធិជាមូលដ្ឋាន ចូល រួមក្នុងការគ្រប់គ្រងធនធានព្រៃសហគមន៍ និងការកែច្នៃអនុផលព្រៃឈើ |
| លទ្ធផលរំពឹងទុក ២.១៖ ៣.៣. សមាជិកសហគមន៍ចំនួន០៣ (សហគមន៍ព្រៃឈើរំដួលវាសនា សហគមន៍ព្រៃឈើសំរែកព្រៃស្រស់ និងសហគមន៍ព្រៃឈើវត្តនរុក្ខា) សមាជិកសហគម ន៍ព្រៃឈើសរុប៤២៦នាក់ និងស្ត្រី១៨៥នាក់ និងបណ្តាញសហគមន៍ ១២នាក់ |

មានស្ត្រីម្នាក់បានយល់ច្បាស់អំពីការបង្កើតសហគមន៍ព្រៃឈើ អត្ថប្រយោជន៍នៃ ការបង្កើតសហគមន៍ព្រៃឈើ ព្រំប្រទល់ព្រៃសហគមន៍ ព្រមទាំងបានចូលរួម ក្នុងសកម្មភាពការពារ និងគ្រប់គ្រងព្រៃសហគមន៍របស់ ពួកគាត់។

| សុចូនករ | ផែនការ១ឆ្នាំ | លទ្ធផល១ឆ្នាំ | ពន្យល់ពីគម្លាត |
|---|---|---|---|
| 3.3.1 ប្រជុំ និងអនុវត្តផែនការប្រចាំត្រីមាសដើម្បីពង្រឹងការគ្រប់គ្រងសហគមន៍របស់គណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ទាំង០៣ និងបណ្តាញសហគមន៍ព្រៃឈើទាំង១២។ | ៣លើក | ១១លើក | ដោយសារការប្រជុំបណ្តាញបានរៀបចំធ្វើឡើងតែ១លើក ព្រោះគណៈកម្មការមិនទាន់មានភាពចាំបាច់ត្រូវប្រជុំ៣ដង ដូច្នេះបណ្តាញសម្រេចចិត្តអោយសម្របសម្រួលប្រជុំតាមសហគមន៍ជាសមាជិកដើម្បីដោះស្រាយបញ្ហាអាទិភាពតាមសហគមន៍ជំនួសវិញជារួមយើងសម្របសម្រួលការប្រជុំរបស់សហគមន៍ជាសមាជិកបណ្តាញថ្នាក់ខេត្តបានចំនួន១១សហគមន៍ចំនួន១១លើក |
| 3.3.2 ការគាំទ្រលើផែនការសហគមន៍រតនរុក្ខា រំដួលវាសនា និងសហគមន៍ភ្នំដងរែកសម្រែកព្រៃស្រស់ និងបណ្តាញសហគមន៍ព្រៃឈើទាំង១២។ | ៦សំណើរ | ១៥សំណើរ | ក្នុងផែនការសហគមន៍២គ្រោងលើកសំណើរ២ធំៗក្នុង១សហគមន៍ ប៉ុន្តែដល់ស្ថានភាពជាក់ស្តែងសំណើរត្រូវបាន បំបែកជាកញ្ចប់តូចៗដែលមានរហូតដល់ទៅ១៥សំណើរសរុបដែលគម្រោងបានឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ក្នុងការដោះស្រាយនិងទប់ស្កាត់ថែរក្សារការពារព្រៃសហគមន៍ |
| 3.3.3 ចូលរួមនិងគាំទ្រក្នុងការបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិភ្នំដងរែកសម្រែកព្រៃស្រស់ | ៨សំណើរ | ១៧សំណើរ | សំណើរគម្រោងផ្តែកលើផែនការយុទ្ធសាស្ត្ររបស់សហគមន៍ដែលបានគម្រោងបានជួយសម្របសម្រួលរៀបចំមានចំនួន៨ ប៉ុន្តែដោយស្ថានភាពជាក់ស្តែងសំណើរទាំង៨ត្រូវបានបំបែកជាអនុសកម្មភាពតូចៗដែលជាសរុបយើងបានឆ្លើយតប១៧សំណើរក្នុងការគាំទ្រលើការបង្កើតសហគមន៍ទេចរធម្មជាតិ |
| 3.3.4 ចូលរួមដំណើរការធ្វើផែនការវិនិយោគ អភិវឌ្ឍន៍ឃុំ និងផែនការរំកិលបថ្នាក់ស្រុក | ២លើក | ៥លើក | ឃុំមិនទាន់មានការរៀបចំផែនការ ព្រោះទើបបោះឆ្នោតឃុំសង្កាត់រួច ថវិកាបានស្នើបង្វែយកប្រើប្រាស់ប្រជុំជាមួយឃុំទៅលើការងារដោះស្រាយបញ្ហាដោះមីននៅដីព្រៃសហគមន៍ និងជួបពិគ្រោះយោបល់លើការស្នើរៀបចំបោះឆ្នោតគណៈកម្មការអាណត្តិថ្មី |

***បរិយាយលំអិតពីលទ្ធផលសម្រេចបានជាព័ត៌មានបែបគុណភាព និងបរិមាណទីនេះ៖***

**3.3.1 ប្រជុំនិងអនុវត្តផែនការប្រចាំត្រីមាស ដើម្បីពង្រឹងការគ្រប់គ្រងសហគមន៍របស់គណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ទាំង០៣ និងបណ្តាញសហគមន៍ព្រៃឈើទាំង១២។**

បុគ្គលិកគម្រោងបានសម្របសម្រួលទំនាក់ទំនងជួបប្រជុំតាមសហគមន៍ចំនួន១១បានចំនួន១៦ដងដែលមានអ្នកចូលរួមសរុប១៧៥នាក់ស្ត្រី៣៨នាក់ ក្រៅពីជួបជាមួយគណៈកម្មការសហគមន៍៣ មានសហគមន៍រតនៈរុក្ខាដែលបានច្របាច់បញ្ចូលជាដែនជម្រកសត្វព្រៃសង្សរុក្ខាវ័ន្ត។ ដោយធ្វើការពិភាក្សាជាមួយគណៈកម្មការសហគមន៍អំពីផែន ការសកម្មភាពដែលសហគមន៍ត្រូវការគាំទ្រពីគម្រោង មានដូចជាការជួយផ្តល់ថវិកា សម្រាប់ដោះស្រាយលើការចុះល្បាតទប់ស្កាត់បទល្មើសក្នុងសហគមន៍ ការគាំទ្រថវិកាសម្របសម្រួលប្រជុំគណៈកម្មការ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ និងដោះស្រាយបញ្ហានានា ដែលកើតមានរង្វង់គណៈកម្មការ

សហគមន៍ ជាពិសេសការពិគ្រោះយោបល់លើការស្នើរុះរើគណៈកម្មការ ផ្លាស់ប្តូរសមាសភាពដឹកនាំតាមរយៈការបោះឆ្នោត និងការតម្រង់ទិសដល់គណៈកម្មការទាំងអស់អោយយល់ពីគោលការណ៍ណែនាំថ្មី ក្រោយពេលសហគមន៍ព្រៃឈើ ត្រូវបានរដ្ឋាភិបាលច្របាច់បញ្ចូលជាដែនជម្រកសត្វព្រៃសង្ឃរុក្ខាវ័ន្ត ដែលដាក់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានវិញ។ ហើយម្យ៉ាងវិញទៀតបុគ្គលិកគម្រោងបានសម្របសម្រួល ជាមួយបណ្តាញសហគមន៍ព្រៃឈើខេត្ត អោយជួយយកចិត្តទុកដាក់សម្របសម្រួលការច្របាច់បញ្ចូលសហគមន៍ ពីការគ្រប់គ្រងស្ថិតក្រោមក្រសួងកសិកម្ម បានផ្ទេរមកដាក់អោយនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថានវិញ ជៀសវាងការភ័នច្រលំអនុវត្តខុសគោលការណ៍ច្បាប់ថ្មី និងអោយបណ្តាញសហគមន៍ព្រៃឈើ ខិតខំដឹកនាំសម្របសម្រួលសហគមន៍ ជាសមាជិកផ្សេងទៀត អោយមានការជួបប្រជុំបានពិភាក្សាដោះស្រាយបញ្ហានានា ដែលកើតមានតាមសហគមន៍មួយៗកុំអោយមើលឃើញថាសហគមន៍ជាសមាជិកនៅឯកោ មិនមានការយកចិត្តទុកដាក់ខ្វាយខ្វល់ពីថ្នាក់ដឹកនាំបណ្តាញ។ បុគ្គលិកគម្រោងក៏បានធ្វើការទំនាក់ទំនង ជាមួយគណកម្មការសហគមន៍ព្រៃឈើរំដួលវាសនា អោយរៀបចំផែនការសកម្មភាពរបស់ខ្លួន ហើយស្នើដាក់ឆ្លងមកកាន់អង្គការកែប្រែសហគមន៍ ដើម្បីពិនិត្យសម្រេចផ្តល់ថវិកាគាំទ្រស្របតាមគោលការណ៍ ដែលអនុលោមទៅតាមខ្ទង់ថវិកា និងគោលនយោបាយចាត់ចែងថវិកា ព្រមទាំងអោយខិតខំពង្រឹងការចូលរួមពីសមាជិកផ្សេងទៀតដើម្បីអោយមានសាមគ្គីភាពរឹងមាំរវាងផ្ទៃក្នុងគណកម្មការ ដើម្បីអាចធ្វើការចុះសម្រុងនឹងគ្នាដោយរលូន ទៅតាមតួនាទីនិងការទទួលខុសត្រូវរបស់ខ្លួន ជាពិសេសការអនុវត្តតួនាទីក្នុងការគ្រប់គ្រងការពារថែរក្សា និងអភិវឌ្ឍព្រៃសហគមន៍ដោយធ្វើការទំនាក់ទំន ងសហការជាមួយអាជ្ញាធរដែនដី មន្រ្តីជំនាញពាក់ព័ន្ធ ដោយមិនត្រូវបណ្តែតបណ្តោយអោយបញ្ហាបទល្មើស កើតមាននៅក្នុងសហគមន៍របស់ខ្លួនដោយពុំមានការអើពើរនោះឡើយ។ យើងក៏បានចុះធ្វើបច្ចុប្បន្នភាពតាមសហគមន៍ដើម្បី ត្រួតពិនិត្យតាមដានការវិវឌ្ឍ និងការរីកចម្រើនរបស់សហគមន៍ធៀបនឹងស្ថានភាពឆ្នាំចាស់ ហើយនឹងរកអោយឃើញ ពីបញ្ហាប្រឈមដែលមានដើម្បីលើកទិសដៅផែនការដោះស្រាយ ព្រមទាំងកសាងផែនការអភិវឌ្ឍអោយចំគោលដៅ។

### 3.3.2 ការគាំទ្រលើផែនការសហគមន៍រតនរុក្ខា រំដួលវាសនា និងសហគមន៍ភ្នំដងរែកសម្រែកព្រៃស្រស់ និងបណ្តាញសហគមន៍ព្រៃឈើទាំង១២

គម្រោងបានធ្វើការសម្របសម្រួលនឹងគាំទ្រដល់សហគមន៍ដែលមានលទ្ធផលសំខាន់ៗដូចខាងក្រោមៈ

1- គាំទ្រសហគមន៍ព្រៃឈើភ្នំដងរែកសម្រែកព្រៃស្រស់ និងរំដួលវាសនា ចុះល្បាតព្រៃ បាន៤ដងមានអ្នកចូលរួមសរុប៤២នាក់ ដោយទទួលបានលទ្ធផលដូចនេះ

- សហគមន៍ព្រៃឈើភ្នំដងរែកសម្រែកព្រៃស្រស់ បានចុះកំណត់ព្រំប្រទល់ ជាមួយសហគមន៍ រំដួលវាសនានិង រលុះធំ
- ចុះចុចGPSបានផ្ទៃដី១០ហិតាកន្លះ លើផ្ទៃដីដែលជន់ល្មើសរុករាន និងដាក់ពាក្យបណ្តឹងទៅតុលា ប្តឹងពីជនល្មើស ឈ្មោះ ប៉ែន ថង អោយបញ្ឈប់សកម្មភាពរុករានដីព្រៃ។

2- គាំទ្រសហគមន៍ព្រៃស្រស់ចូលរួមធ្វើបទបង្ហាញពីគម្រោង និង ផែនការអភិវឌ្ឍន៍ទៅដល់ម្ចាស់ជំនួយ កំពុងពេលវេទិការនាយក នៅប្រាសាទតាក្របី

3- គាំទ្រសហគមន៍ព្រៃស្រស់ចូលរួមទិវាដាំកូនឈើនៅសង្ឃរុក្ខាវ៉ន ពោលគឺដើមឈើចំនួន៦៣ាន់ ត្រូវបានដាំលើដីរិចរិល៥ហិតាដើម្បីស្តារព្រៃឡើងវិញ បំពេញកន្លែងរិចរិល ដែលគ្មានគម្របការពារ ក្នុងដីព្រៃសហគមន៍ សង្ឃរុក្ខាវ័ន្ត។ កូនឈើរួមមានកូនក្រញូង បេង គគី ធ្នង់ ត្រាច ត្បែង ស្តុំ កាស្យា ម្តេញ កំពេញរាជ និង ដើមឈើហូបផ្លែមួយចំនួនទៀត។

4- តំណាងអង្គការCTO ចូលរួមសម្របសម្រួលនិងអង្កេតការ នៃដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងព្រៃឈើរតនៈរុក្ខា សមាសភាពចូលរួមសំខាន់សំខាន់មាន ក្រុមប្រឹក្សាសង្កាត់កូនក្រៀល2នាក់ ក្រុមប្រឹក្សាសង្កាត់សំរោង2នាក់ មន្ត្រីក្រសួងបរិស្ថាន4នាក់ ប្រធានភូមិទាំង6ភូមិ 6នាក់ បុគ្គលិកនៃអង្គការកែប្រែសហគមន៍(C.T.O) 2នាក់និងប្រជាពលរដ្ឋទាំង6ភូមិ ក្នុងនោះមាន ភូមិតាម៉ាន ភូមិខ្ទុំ ភូមិបុស្ស និងភូមិបាក់នឹម មន្ត្រីបរិស្ថាន02នាក់

5- ចុះល្បាតព្រៃរបស់រតនៈរុក្ខាមានសមាជិកតាមភូមិ មកពី 4ភូមិ ក្នុងនោះមានភូមិ តាម៉ាន ភូមិខ្វរ ភូមិបុស្ស និងភូមិ បាក់នឹម មន្ត្រីបរិស្ថាន02 នាក់មិនបានជួបប្រទះបទល្មើសអ្វីទេ បានត្រឹមឃើញស្លាកស្នាមឈើដែលជនល្មើសបានលួចកាត់ដឹកនៅខាងក្រៅ។

6- ចុះល្បាតព្រៃរបស់រតនៈរុក្ខាធ្វើដំណើរដោយគោយន្តមួយគ្រឿង និងម៉ូតូ០២គ្រឿង ដែលមានអ្នកចូលរួមមកពី០៤ភូមិ មានភូមិតាម៉ាន ភូមិខ្ញុំ ភូមិបុស្ស ភូមិបាក់នឹម និងភូមិកូនដំរី សរុបអ្នកចូលរួម១៦នាក់ ក្នុងនោះមានស្ត្រី០៤ នាក់បានឃើញស្ថានភាពព្រៃឈើ ហាក់មានភាពស្ងប់ស្ងាត់ល្អមិនមានកន្លែងស្លាកស្នាម ដែលជនល្មើសកាប់ ទាំងចាស់ និងថ្មីទេ ព្រោះគណៈកម្មការបានចុះញឹកញ៉ាប់ចឹង អាចធ្វើឲ្យបទល្មើស ខ្លាចរអារមិនហ៊ាន ចូលលួចឈើទេ។

7- ចុះល្បាតព្រៃរបស់រតនៈរុក្ខាធ្វើដំណើរដោយគោយន្តមួយគ្រឿង និងម៉ូតូ០២គ្រឿង ដែលមានអ្នកចូលរួមមកពី០៤ភូមិ មានភូមិតាម៉ាន ភូមិខ្ញុំ ភូមិបុស្ស ភូមិបាក់នឹម និងភូមិកូនដំរី សរុបអ្នកចូលរួម១៨នាក់ ក្នុងនោះមានស្ត្រី០៤នាក់ ដកហូតបានម៉ាស៊ីនមួយគ្រឿង និងឈើច្រៀកស្រាច់ចំនួនកន្លះគីប ពីជនល្មើស ហើយបានបញ្ជូនទៅរក្សាទុកនៅការិយាល័យបរិស្ថាន។

8- ប្រជុំគណៈកម្មការនិងចុះល្បាតព្រៃសហគមន៍ព្រៃស្រស់ដើម្បីពិភាក្សារនូវ
   - ការរៀបចំគណៈកម្មការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងព្រៃឈើតាមលក្ខន្តិកៈអាណត្តិ៥ឆ្នាំម្តង
   - ចុះល្បាតព្រៃនៅពេលរសៀលម៉ោង២និង៤២នាទី ពិនិត្យទីតាំងកាប់បំផ្លាញព្រៃឈើ ប៉ុន្តែមានភ្លៀងខ្លាំងទើប មិនបានកំណត់លេខនិយាមករ។

9- ចុះជម្រើននិងបច្ចុប្បន្នភាពសហគមន៍ 1.អូរយាយកែវ ១២នាក់ ស្រី៥នាក់ 2. ឈូកមាស ១០នាក់ ស្រី៦នាក់ 3. រលុះធំ ១១នាក់ ស្រី៦នាក់ 4. ដុងបេង ៩នាក់ ស្រី៧នាក់ 5. អណ្តូងបរ ១៣នាក់ ស្រី៤នាក់ 6. រំដួលវាសនា ១០នាក់ ស្រី0នាក់ 7. ព្រៃស្រស់ ១២នាក់ ស្រី៥ 8. រតនៈរុក្ខា ១០នាក់ ស្រី៤នាក់ 9. សាមគ្គី ១២នាក់ ស្រី៧នាក់ 10. អូរទឹកខៀវ ៩នាក់ ស្រី៥នាក់ 11. អូរសូភីគីរីព្រៃស្រោង ១១នាក់ ស្រី៦នាក់ 12. សាមគ្គីសង្គ្រោះព្រៃឈើ ១០នាក់ ស្រី១ មានអ្នកចូលរួមសរុប ១២៤នាក់ ស្រី៥៦នាក់

10- ប្រជុំដោះស្រាយបញ្ហាការងារគណៈកម្មការចាស់ និង គណៈកម្មការថ្មី ព្រៃស្រស់ អភិបាលរងស្រុក ក្រុមប្រឹក្សាស្រុក មេភូមិចំណុះសហគមន៍ គណៈកម្មការសហគមន៍ មេឃុំគោកខ្ពស់ នាយរងសង្កាត់រដ្ឋបាលព្រៃឈើ អនុការីក.ធ.ប។ លោកអភិបាលរងស្រុកបានបញ្ជាក់អំពីបញ្ហាដែលកើតមាននៅសហគមន៍ និងអោយលោក ត្រែន ត្រៃ ប្រធានសហគមន៍ចាស់ពិចារណាលើ៤ចំនុន ៖
   1. សុំអោយរុះរើ រោងចេញពីសហគមន៍ជាបន្ទាន់
   2. ទុកដីអោយអាស្រ័យផលធម្មតា
   3. អោយសរុបតម្លៃធ្វើរោងអស់ប៉ុន្មាន
   4. បើមិនព្រម រុះរើរោងចេញពីសហគមន៍ទេ សាលាស្រុកនឹងចាត់វិធានការតាមផ្លូវច្បាប់

### 3.3.3 ចូលរួមនិងគាំទ្រក្នុងការបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិភ្នំដងរែកសម្រែកព្រៃស្រស់។

ក្រោយពីរដ្ឋបាលខេត្តបានចេញលិខិតអនុញ្ញាតិ អោយសហគមន៍រៀបចំអភិវឌ្ឍកែច្នៃសហគមន៍ព្រៃឈើប្រែ ក្លាយទៅជាសហគមន៍ទេសចរណ៍ធម្មជាតិ តាមសំណើរបស់គណៈកម្មការសហគមន៍រួចមក យើងបានរៀបចំផែនការរួមគ្នាជាមួយគណៈកម្មការសហគមន៍ព្រៃឈើ ដោយចាត់ចែងប្រើប្រាស់ធនធានថវិកាគម្រោង ដែលមានប្រចាំឆ្នាំផ្តោតលើការចាត់ចែងលើផែនការសកម្មភាព ដែលបានរៀបចំរួមគ្នាជាជំហ៊ានៗតាមដំណាកកាលនិងលទ្ធភាព។ បន្ថែមពីហ្នឹងថវិកាក៏ប្រើប្រាស់ដើម្បីអោយគណៈកម្មការអាចរៀបចំការប្រជុំដោះស្រាយការងារ ព្រមទាំងចុះល្បាតទប់ស្កាត់ បទល្មើសដែលកើតមាននៅសហគមន៍ ក៏ដូចជាឡើងចុះទំនាក់ទំនងជាមួយអាជ្ញាធរ ដើម្បីគាំទ្រទៅលើការដោះស្រាយបញ្ហាប្រឈមដែលកើតមាន។ នៅឆមាសទី១ នាយកប្រតិបត្តិអង្គការក៏បានចុះមកជួយសម្របសម្រួលការងារបច្ចេកទេស លើដំណើរការរៀបចំអនុវត្តសកម្មភាពរួមគ្នា ដើម្បីអោយការប្រើប្រាស់ធនធានថវិកាគម្រោងមានប្រសិទ្ធិភាពចំគោលដៅ ព្រមទាំងចុះសិក្សាលំអិតរួមគ្នានៅទីតាំង ដែលត្រូវគ្រោងរៀបចំកសាងហេដ្ឋារចនាសម្ព័ន្ធ

រូបវន្តដែលចាំបាច់ហើយគម្រោងមានលទ្ធភាពគាំទ្របាន។ ហើយចំណែកសកម្មភាពណាដែលហួសពីលទ្ធភាពគម្រោងមាននឹងជួយគណៈកម្មការរៀបចំផែនការកៀរគរធនធានពីប្រភពផ្សេងៗ ដើម្បីចូលរួមជម្រុញការអភិវឌ្ឍអោយដើរទៅមុខតាមផែនការអភិវឌ្ឍដែលបានគ្រោង។ នាយកប្រតិបត្តិក៏បានធ្វើផែនការរួមជាមួយសហគមន៍ដើម្បីត្រៀមរៀបចំ ទទួលគណៈប្រតិភូនាយកនាយិកាក្រុមខ័ណ្ឌគម្រោងLRPរៀបចំកិច្ចប្រជុំវេទិកានាយកនៅតំបន់សហគមន៍។

គាំទ្រការប្រជុំប្រចាំខែរបស់គណៈកម្មការសហគមន៍ព្រៃឈើភ្នំដងរែកសម្រែកព្រៃស្រស់ចំនួន៣ដង៖

១-ប្រជុំការគ្រប់គ្រងតំបន់អេកូទេសចរណ៍ និង បែងចែកតួនាទី អ្នកទទួលខុសត្រូវរបស់គណៈកម្មការ

២-ប្រជុំធ្វើផែនការសម្រាប់២០២២ លើការអភិវឌ្ឍន៍តំបន់អេកូទេសចរណ៍

៣-ប្រជុំពិភាក្សាស្ដីពីការធ្វើជណ្ដើរឡើងប្រាសាទតាក្របី និងពង្រឹងជួរគណកម្មាការ

តាមរយៈកិច្ចប្រជុំខាងលើនេះទទួលបានលទ្ធផលដូចតទៅ៖

<u>លទ្ធផលប្រជុំលើកទី១</u>

- ការរៀបចំតំបន់ទេសចរណ៍ធម្មជាតិសហគមន៍ត្រូវបានអនុញ្ញាតិ និងមានការគាំទ្រពីអាជ្ញាធរជាផ្លូវការ។
- តួនាទីរបស់ជួរគណៈកម្មការ ត្រូវបានចាត់ចែកទៅតាមយ៉ាងត្រឹមត្រូវ

<u>លទ្ធផលប្រជុំលើកទី២</u> សហគមន៍បានឯកភាពគ្នា៖

- រៀបចំក្រាលគ្រួសក្រហមលើផ្លូវដីសចំនួន៥០០ម៉ែត្រ ពីផ្លូវយុទ្ធសាស្ត្រទៅជើងភ្នំប្រាសាទតាក្របី ដែលបានសាងសង់រួចរាល់ក្នុងឆ្នាំ២០២១តាមរយៈការគាំទ្រគម្រោងបដិភាគជាមួយមន្ទីរកសិកម្ម។
- ធ្វើការសម្អាតផ្លូវ និងតភ្ជាប់បណ្ដាញខ្សែអគ្គិសនីដាក់អំពូលភ្លើងទៅឡើងប្រាសាទតាក្របីចំនួន៣៥០០ម៉ែត្រ
- នាយផ្នែករដ្ឋាលព្រៃឈើជួយកូនឈើ១០០ដើមសម្រាប់ដាំតាមដងផ្លូវចូលទៅមាត់ព្រៃសហគមន៍

<u>លទ្ធផលប្រជុំលើកទី៣</u>

គណៈកម្មការឯកភាពយល់ព្រម ធ្វើផ្លូវដើរឡើងប្រាសាទតាមក្របីសម្រាប់អ្នកដំណើរថ្មើរជើង ដែលងាយស្រួលហើយចំណាយពេលវេលាតិច ដើម្បីទៅលេងប្រាសាទតាក្របី ដោយពុំបាច់ធ្វើដំណើរវាងរយៈចំងាយជិត៤០គមទៅមក។ សកម្មភាពនេះត្រូវបន្តនៅត្រីមាសទី២ទៀតដែលមានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

1- ប្រជុំគណៈកម្មការរៀបចំធ្វើផែនការអភីវឌ្ឍនតំបន់អេកូទេសចរណ៍នៅភ្នំដង់រែកសម្រែកព្រៃស្រសដែលមានប្រធានសហគមន៍ ១នាក់គណៈកម្មការ ៨នាក់និង បុគ្គលិក CTO ១នាក់ បានប្រជុំពីភាក្សាពីគម្រោងធ្វើផ្លូវថ្មើរជើងនិងកាំជណ្ដើរឡើងប្រាសាទតាក្របី ដាក់គោលដៅថ្ងៃទី៧ ខែមិថុនា ២០២២ ចុះវាស់វែងជាក់ស្ដែង

2- បុគ្គិលកចូលរួមប្រជុំគណៈកម្មការរៀបចំធ្វើផែនការអភីវឌ្ឍនតំបន់អេកូទេសចរណ៍នៅភ្នំដង់រែកសម្រែកព្រៃស្រសដែលមានអ្នកចូលរួមប្រធានសហគមន៍១នាក់គណៈកម្មការ ៨នាក់ និង បុគ្គលិក CTO១នាក់ ប្រជុំពង្រឹងផ្ទៃក្នុងពង្រឹងសមត្ថភាពជួយគណៈកម្មការ និង តួនាទីគណៈកម្មការគ្រប់គ្រង តំបន់អេកូទេសចរ

3- ប្រធានសហគមន៍ ១នាក់ គណៈកម្មការ ៤នាក់ និង បុគ្គលិក CTO ២នាក់ ប្រជុំពិភាក្សាពីគម្រោងសាងសង់ជណ្ដើរឡើងភ្នំប្រាសាទតាក្របី ចុះសិក្សា និងវាស់វែងពីខាងក្រោមភ្នំ ដល់លើភ្នំមានប្រវែងជាក់ស្ដែង៥០០ម៉ែត្រ សម្រាប់ផ្លូវថ្មើរជើងឡើងប្រាសាទតាក្របី ក្នុងនោះប្រវែង២៥០ម៉ែត្រ គណៈកម្មការចង់ធ្វើខ្ទះ១សម្រាប់ សម្រាកជើងបំបាត់ហត់ និង នៅលើភ្នំដីរាបស្មើធ្វើខ្ទុះ១ទៀតសម្រាប់សម្រាកលំហែមើលទេសភាព។ ចំពោះជណ្ដើរដែលត្រូវធ្វើមាន១២កន្លែង កន្លែងខ្លះត្រូវធ្វើ៣កាំ ៤កាំ ៥កាំ និង៦កាំ។

4- CTO និង សហគមន៍ទិញសម្ភារៈសម្រាប់តំបន់អេកូទេសចរ។ សម្ភារៈដែលប្រគល់អោយសហគមន៍ព្រៃស្រស់រួមមាន កៅស៊ូស សម្រាប់បាំងតង់ការពារភ្លៀង ចំនួន ៥២.៥ម៉ែត្រ ខ្សែខ្មៅសម្រាប់ចងកៅស៊ូស ១ដុំ ការ៉ុងសម្រាប់ច្រកសម្ភារៈ ១៥ការ៉ុង ខ្មើយកើយ ១៥ខ្មើយ ភួយ ១០ស្លឹក កន្ទេលជ័រ ៥សន្លឹក។

5- ប្រជុំគណៈកម្មការព្រៃស្រស់ ធ្វើផែនការបន្ត សម្រាប់តំបន់ទេសចរ ពីភាក្សាលំអិតអំពី ធ្វើផ្លូវឡើងប្រាសាទតាក្របី ធ្វើបង្កាន់ដៃ ជណ្តើរតាមចំណោត និងកន្លែងសម្រាក៣កន្លែង ធ្វើអាហារដ្ឋាន ដាក់អំពូលភ្លើងបំភ្លឺពេលយប់ រៀបចំកន្លែងសម្រាប់ភ្ញៀវថតរូបអនុស្សាវរីយ៍ និង បង្កើនខ្ទះ៥បន្ថែមទៀតភ្ជាប់គ្នាពីមួយទៅមួយ ជារង្វង់ និង ចំកណ្តាលធ្វើសាលប្រជុំ ឬកន្លែងទទួលភ្ញៀវ។

6- CTO និង សហគមន៍ប្រជុំពិភាក្សាពីការធ្វើរោងដាក់ឡាន និង សាលប្រជុំនៅព្រៃស្រស់។ អង្គប្រជុំបានឯកភាពគ្នារៀបចំធ្វើរោងដែលមានទំហំ ១២ម x ៦ម ដែលសរុប១៩០០ដុល្លារ ដោយមានបដិភាពពីសហគមន៍នូវឈើនិងកម្លាំងពលកម្ម។

7- គម្រោងបានគាំទ្រសហគមន៍ដើម្បីសាងសង់សាលប្រជុំសហគមន៍ទំហំ៦ម x ១២ម ធ្វើពីឈើប្រក់ស័ង្កសី

**3.3.4 ចូលរួមដំណើរការធ្វើផែនការវិនិយោគ អភិវឌ្ឍន៍ឃុំ និងផែនការវិកិលបថ្នាក់ស្រុក**

កាលពីឆមាសទី១គណកម្មការសហគមន៍ព្រៃស្រស់ បានចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំចំនួន២ដង ដើម្បីធ្វើរបាយការណ៍ទៅក្រុមប្រឹក្សាឃុំ និងសុំការអន្តរាគមន៍ចំពោះការចាត់វិធានការ ទៅលើបទល្មើសដែលកើតមាននៅ ក្នុងសហគមន៍ ព្រមទាំងពិភាក្សាអំពីផែនការរៀបចំបោះឆ្នោតរុះរើគណកម្មការ។ ចំណែកសហគមន៍ព្រៃឈើរំដួល វាសនា បានស្នើរធ្វើសកម្មភាពជួបជាមួយក្រុមប្រឹក្សាឃុំ១ដង ដើម្បីធ្វើការងារដោះស្រាយលើការងារចុះដោះមីននៅក្នុងតំបន់សហគមន៍ ដើម្បីសុវត្ថិភាពប្រជាពលរដ្ឋ ដែលចុះឆ្លងកាត់ក្នុងតំបន់សហគមន៍ ព្រោះតំបន់ក្នុងព្រៃសហគមន៍មួយផ្នែកនៅមានការសង្ស័យពីបញ្ហាមីន ហើយមិនធ្លាប់មានប្រវត្តិបោសសំអាតពីមុនមក។ បន្ទាប់មកគណៈកម្មការសហគមន៍ក៏បានឡើងមកជួបនៅសាលាក្រុង និងរដ្ឋបាលព្រៃឈើដើម្បីដាក់របាយការណ៍ស្តីពីស្ថានភាពសហគមន៍។ សកម្មភាពដំណើរការផែនការវិនិយោគឃុំ នៅដើមឆ្នាំ២០២២នេះ មិនទាន់មាននៅឡើយទេ ស្របពេលដែលពេលវេលានេះ ជាពេលដែលមានការរៀបចំបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់។ ដូចនេះសកម្មភាពចូលរួមដំណើរការផែនការវិនិយោគ អភិវឌ្ឍឃុំនឹងត្រូវរង់ចាំរហូតដល់មានការរៀបចំជាក់ស្តែងនៅពេលក្រោយ។

គោលបំណងទី៤៖ ៤.១ សកម្មភាពការត្រៀមបម្រុង សម្រាប់ដើម្បីឆ្លើយតបទៅនិងគ្រោះមហន្តរាយក្នុងខេត្តឧត្តរមានជ័យ។ ផ្តល់សម្ភារៈនិងស្បៀងសង្គ្រោះបន្ទាន់ប្រជាជនភូមិគោលដៅក្រ១ឬក្រ២នៅពេលជួបគ្រោះមហន្តរាយ។

**លទ្ធផលរំពឹងទុកទី ៤.១៖** ជនងាយរងគ្រោះ មានកុមារ ចាស់ជរា គ្រួសារក្រីក្រ ក្នុងឃុំគោលដៅគម្រោងទាំង៥អាចធន់ទ្រាំនិងការប្រែប្រួលអាកាសធាតុ និងត្រៀមលក្ខណៈបង្កា អាចឆ្លើយតបគ្រោះមហន្តរាយដែលកើតឡើងដោយប្រការណាមួយ។

| សុចនករ | ផែនការ១ឆ្នាំ | លទ្ធផល១ឆ្នាំ | ពន្យល់ពីគម្លាត |
|---|---|---|---|
| 4.1. ត្រៀមបង្កា និងឆ្លើយតបគ្រោះមហន្តរាយ | 0ករណី | 0ករណី | មិនមានករណីគ្រោះមហន្តរាយកើតមានទេក្នុងកំឡុងពេលហ្នឹងហើយថវិកាបានស្នើបង្វែយកទៅប្រើប្រាស់ក្នុងគោលបំណងសកម្មភាពផ្សេង |

**4.1. ត្រៀមបង្កា និងឆ្លើយតបគ្រោះ មហន្តរាយ**

មិនមានករណីគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើងទេ នៅតំបន់គោលដៅគម្រោងនៅឆ្នាំនេះ។ យ៉ាងណាក៏ដោយបុគ្គលិកគម្រោងបានចុះសម្របសម្រួល ជាមួយគណៈគ្រប់គ្រងសាលាបឋមសិក្សាថ្មល់បត់ ដើម្បីពិភាក្សាអំពីការតម្លើងផ្លាកអប់រំស្តីពីច្បាប់ចរាចរណ៍ និងហានិភ័យស្តីពីគ្រោះថ្នាក់ចរាចរណ៍។ រហូតដល់ចុងឆ្នាំដោយថវិកានេះមិនបានប្រើប្រាស់ យើងក៏បានស្នើបង្វែថវិកាយកទៅប្រើប្រាស់ក្នុងសកម្មភាពកិច្ចប្រជុំវេទិកានាយកលើកទី២ និងសិក្ខាសាលាកម្មវិធីកុមារប្រចាំឆ្នាំ។

**គោលបំណងទី៧៖ ៧.ជំរុញការអនុវត្តគោលនយោបាយ និងគោលការផ្ទៃក្នុងរបស់អង្គការកែប្រែសហគមន៍ តាមរយៈការពង្រឹងសមត្ថភាពគណគ្រប់គ្រង និងបុគ្គលិ កលើការគ្រប់គ្រង និងត្រួតពិនិត្យ ការអនុវត្តន៍គម្រោង និងស្ថាប័ន។**

**លទ្ធផលរំពឹងទុកទី ៧.១៖** ៧.១. បុគ្គលិកអង្គការកែប្រែសហគមន៍ ចំនួន៦នាក់/ស្រី៤នាក់ ទទួលបានចំ ណេះដឹងថ្មីៗតាមរយៈការចូលរួមសិក្ខាសាលា ការប្រជុំ បណ្តាញអង្គការដៃគូរ នានាទាំងក្នុងខេត្ត និងក្រៅខេត្ត និងអនុវត្តគោលនយោបាយរបស់ខ្លួន។

| សុចនករ | ផែនការ១ឆ្នាំ | លទ្ធផល១ឆ្នាំ | ពន្យល់ពីគម្លាត |
|---|---|---|---|
| 7.1. សិក្ខាសាលាភាពជាដៃគូ និងរៀបចំផែនការការយុទ្ធសាស្ត្រជាមួយនឹង AAC | ៣លើក | ៤លើក | -វេទិកានាយក ឧត្តរមានជ័យ<br>-សិក្ខាសាលា NRM&LLS<br>-សិក្ខាសាលារៀបចំផែនការ២០២៣<br>-វេទិកានាយក កោះកុង |
| 7.2. ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ | ១ដង | ១ដង | ប្រជុំបុគ្គលិកនិងក្រុមប្រឹក្សាភិបាល |
| 7.3. ត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំឆមាស (comprehensive monitoring) | ២ដង | ៨ដង | ចុះត្រួតពិនិត្យរួមជាមួយក្រុមការងារហិរញ្ញវត្ថុ១ដងក្រៅពីហ្នឹងគឺគណៈគ្រប់គ្រង និងមន្ត្រីហិរិញ្ញវត្ថុចុះត្រួតពិនិត្យប្រចាំនៅទីវាលតំបន់គោលដៅ |
| 7.4. រៀបចំ និងត្រួតពិនិត្យផែនការឆ្នាំ ២០២២ | ១ដង | ០ដង | គ្រោងធ្វើសកម្មភាពនៅខែ១១ ប៉ុន្តែជាក់ស្តែងខាងAACបានដាក់អោយរៀបចំពង្រៀងផែនការ២០២៣ផ្ញើទៅAACវិញក្នុងខែ៩ នាំអោយខកពេលមិនអាចអនុវត្តសកម្មភាពនេះបានភ្លាមៗព្រោះដឹងផែនការប្រថុចញ៉ុចពេក |
| 7.5. បង្ហាញ គម្រោងប្រចាំឆ្នាំដំបូងដល់អ្នកពាក់ព័ន្ធ | ១ដង | ១ដង | បញ្ចប់រួចរាល់ |
| 7.6. ពង្រឹងសមត្ថភាពអង្គភាព | ៤ដង | ៥ដង | -CCC nnnual membership fee<br>-MEL workshop<br>-ArcGIS/ArcGIS Pro & CarryMaps software<br>-CTO website maintenance<br>-Training on ArcGIS/CarryMaps<br>-Printing Policy to distribute to stakeholder<br>-Copy support document for Quickbook to 8 partners |

**7.1. សិក្ខាសាលាភាពជាដៃគូ និងរៀបចំផែនការការយុទ្ធសាស្ត្រជាមួយនឹង AAC**

នៅខែមេសា២០២២ អង្គការកែប្រែសហគមន៍ធ្វើជាម្ចាស់ផ្ទះ សម្របសម្រួលដឹកនាំកិច្ចប្រជុំវេទិកានាយក ជាមួយអង្គការដៃគូរក្របខ័ណ្ឌគម្រោងLRPទាំង៥ខេត្ត ដើម្បីធ្វើរបាយការណ៍រីកចម្រើនពីវឌ្ឍនភាពគម្រោងនីមួយៗ និងការឆ្លុះបញ្ចាំងនូវលទ្ធផល ដែលសម្រេចបានពីគ្នាទៅវិញទៅមក។ ធ្វើបទបង្ហាញចែករំលែកបទពិសោធន៍ ក្នុងការស្នើរសុំប្រើប្រាស់ភាសាទៅកាន់និយ័តករគណនេយ្យ និងសវនកម្ម ពីអង្គការដៃគូរដែលបានធ្វើកិច្ចការនេះបានជោគជ័យ។ បទបង្ហាញពីអនុលោមភាពគោលនយោបាយនានា ក្នុងក្របខ័ណ្ឌគម្រោងLRP និងឆ្លុះបញ្ចាំងការអនុវត្តជាក់ស្តែង ហើយនឹងជម្រុញការរៀបចំ និងអនុវត្តគោលនយោបាយ ដែលតម្រូវដោយម្ចាស់ជំនួយអោយបានខ្ជាប់ខ្ជួន។ ការធ្វើបទបង្ហាញពីអាណានិគមន៍ជំនួយ យុត្តិធម៌អាកាសធាតុ ធ្វើការឆ្លុះបញ្ចាំងរួមគ្នាពីផែនការដែលត្រូវធ្វើសម្រាប់៥ឆ្នាំបន្ត ការចែករំលែកពីគោលនយោបាយហិរញ្ញវត្ថុតាមអង្គការនីមួយៗ ក៏ដូចជាបង្ហាញពីបទពិសោធន៍ក្នុងភាពជាអ្នកដឹកនាំ និងយុទ្ធសាស្ត្រនៃការគៀគរថវិកាសម្រាប់ទ្រទ្រង់ស្ថាប័ន។ ធ្វើការចែករំលែកឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រ ក្នុងការពង្រឹងប្រសិទ្ធភាពជួយដល់សហគមន៍ ព្រមទាំងចូលរួមផ្តល់មតិយោបល់ លើការធ្វើបទបង្ហាញផែនការអភិវឌ្ឍតំបន់ទេសចរធម្មជាតិ នៅប្រាសាទតាក្របីរបស់សហគមន៍ព្រៃឈើសម្រែកព្រៃស្រស់ ការរិតចំណងមិត្តភាពសាមគ្គីរវាងសហគមន៍ និងដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសថៃនៅមហាវិទ្យាល័យរជមង្គល អំពិកម្មវិធីវិទ្យាសាស្ត្រកសិកម្ម។

សិក្ខាសាលាឆ្លុះបញ្ចាំងនិងសិក្សារៀនសូត្រអំពីការអនុវត្តល្អ បញ្ហាប្រឈមកម្មវិធីគ្រប់គ្រងធនធានធានធម្មជាតិ និងកម្មវិធីបំណិនជីវិតតាមសាលាដែលអង្គការដៃគូរនីមួយៗ កំពុងអនុវត្តគម្រោងព្រមទាំងបទឧទ្ទេសក៏ចែករំលែកខ្លឹមសារ និងគោលការណ៍ណែនាំដើម្បីជម្រុញការអនុវត្តកម្មវិធីបំណិនជីវិតអោយបានសមស្របដោយមន្ត្រីជំនាញក្រសួងអប់រំ។

សិក្ខាសាលារៀបចំផែនការនិងថវិកាសម្រាប់ឆ្នាំ២០២៣ ដើម្បីអោយមានការបន្សុីគ្នាទៅនឹងគោលដៅយុទ្ធសាស្ត្រព្រមទាំងតម្រូវការអាទិភាពរបស់គម្រោងនិងអ្នកទទួលផល។

វេទិកានាយកលើកទី២ដែលប្រព្រឹត្តទៅនៅខេត្តកោះកុង រួមបញ្ចូលកម្មវិធីទស្សនកិច្ចទៅកាន់ប្រទេសថៃ។

### 7.2. ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ(សៀមរាប)

ការប្រជុំនេះមានមានសមាសភាពបុគ្គលិកទាំងអស់និងក្រុមប្រឹក្សាភិបាលក្នុងគោលបំណងដើម្បីពិភាក្សាអំពី៖

- ធ្វើរបាយការណ៍សង្ខេបអំពីលទ្ធផលសំខាន់ៗនៃការអនុវត្តកម្មវិធីគម្រោង
- ឆ្លុះបញ្ចាំងពីស្ថាប័នទៅលើការលទ្ធផលនៃការវាយតម្លៃ តាមវិធីសាស្ត្រ ITOCA ដើម្បីរកនូវចំណុចខ្លាំង ចំនុចខ្វះខាតស្ថាប័នក្នុងការរកដំណោះស្រាយរួមគ្នា និងលើកទិសដៅដាក់ផែនការក្នុងការអភិវឌ្ឍកែលំអរ
- ពិភាក្សាដោះស្រាយនូវបញ្ហាប្រឈមនានាដែលកើតមានចំពោះមុខ និងកង្វល់ផ្សេងៗដែលបុគ្គលិកមាន
- ឆ្លុះបញ្ចាំងនិងចែករំលែកទៅលើការអនុវត្តគោលនយោបាយដែលមានយូរហើយ និងគោលនយោបាយថ្មីៗ
- ពិនិត្យលើអនុសាសន៍នានាដែលមានជុំវិញការចុះត្រួតពិនិត្យវាយតម្លៃការងារគម្រោងរបស់ម្ចាស់ជំនួយ
- ពិភាក្សាអំពីយុទ្ធសាស្ត្រ៥ឆ្នាំទៅខាងមុខយោងលើផែនការយុទ្ធសាស្ត្រនិងស្ថានភាពវិវឌ្ឍនៃសង្គម
- ពិភាក្សាលើបញ្ហាការស្នើរសុំធ្វើបច្ចុប្បន្នភាពអង្គការអោយស្របតាមច្បាប់LANGOs

### 7.3. ត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំឆមាស

បុគ្គលិកបានចុះជួបប្រជុំ ជាមួយក្រុមគោលដៅគម្រោងចំនួន១៨ដង ទៅសហគមន៍ព្រៃឈើ៨ដង សាលារៀនគោលដៅគម្រោងចំនួន៧ដង ជួបជាមួយអ្នកទទួលផល ជាសិស្សនិងសមាជិកសហគមន៍ព្រៃឈើ ដើម្បីធ្វើករណីសិក្សាចំនួន៣ដង។ នាយកនិងប្រធានហិរញ្ញវត្ថុប្រចាំនៅការិយាល័យសៀមរាបបានចុះទៅពិនិត្យ ដោះស្រាយបញ្ហាការងារនៅការិយាល័យឧត្តរមានជ័យចំនួន៤ដង រួមទាំងការចូលរួមជាមួយក្រុមការងារមន្ត្រីជំនាញគ្រប់គ្រងហិរញ្ញវត្ថុ អង្គការអាក់សិនអេដដើម្បីធ្វើការត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុនិងលទ្ធផលការងារដែលសម្រេចបាន ក្រោយពីអាក់ខានចុះត្រួតពិនិត្យមកជាង២ឆ្នាំដោយសាបញ្ហារាតត្បាតជំងឺកូវីដ១៩

### 7.4. រៀបចំ និងត្រួតពិនិត្យផែនការឆ្នាំ២០២២

សកម្មភាពនេះត្រូវបានខកខានមិនអាចធ្វើបាន ដោយសារមានកំហុសឆ្គងលើការរៀបចំកាលវិភាគសម្រាប់ចាត់ចែងអនុវត្តសកម្មភាពមិនបានច្បាស់លាស់ ដោយការភ័ណ្ឌច្រលំពេលវេលារវាងCTOជាមួយAAC។ ក្នុងពេលរៀបចំផែនារប្រចាំត្រីមាស យើង

បានដាក់សកម្មភាពហ្នឹងក្នុងត្រីមាសចុងក្រោយ ដែលរំពឹងថានឹងរៀបចំក្នុងខែវិច្ឆិកា ប៉ុន្តែជាក់ស្តែងការប្រមូលពង្រៀងផែនការ និងថវិកា២០២៣ត្រូវបានខាងAAC តម្រូវអោយរៀបចំតាំងក្នុងខែកញ្ញាត្រីមាសទី៣ក្នុងឆ្នាំ២០២២ ជាហេតុនាំអោយយើងមិនអាចរៀបចំការប្រជុំត្រួតពិនិត្យផែនការ បានទាន់ពេលដែលខាងក្រុមការងារ បានជូនដំណឹងមកចំពេលប្រចុចញ៉ិចពេក មិនអាចរៀបចំប្រជុំត្រួតពិនិត្យបានទាន់ទើបសកម្មភាពនេះ ត្រូវបានខកខានមិនអាចអនុវត្តបាន ហើយថវិកាត្រូវបានសល់មិនបានប្រើប្រាស់។

**7.5. បង្ហាញ គម្រោងប្រចាំឆ្នាំដំបូងដល់អ្នកពាក់ព័ន្ធ**

ប្រជុំធ្វើបទបង្ហាញស្តីពីលិទ្ធផលសម្រេចក្នុងឆ្នាំ២០២១ និងផ្សព្វផ្សាយពីផែនការបន្តសម្រាប់ឆ្នាំ២០២២ ដល់អ្នកពាក់ព័ន្ធដែលមានអ្នកចូលរួម ២៤នាក់មកពីអាជ្ញធរឃុំសង្កាត់ វិស័យអប់រំ រដ្ឋាលព្រៃឈើ តំណាងបណ្តាញសហគមន៍ព្រៃឈើ និងគណៈកម្មការសហគមន៍ព្រៃឈើ។ អ្នកចូលរួមមានមកពីតំណាងមន្ទីរអប់រំខេត្ត ប្រធានការិយាល័យការិយាល័យបឋមសិក្សា តំណាងឃុំសង្កាត់ (បន្សាយរាក់ សំរោង កូនក្រៀល ពង្រ និងគោកខ្ពស់) នាយកសាលា(បាក់នឹម រំដួលវាសនា បន្ទាយជ័រ ពង្រនិងអំពិល) គណៈកម្មការសហគមន៍ព្រៃឈើ (រំដួលវាសនា ឈូកមាស រតនៈករុក្ខា ព្រៃស្រស់) ដែលរៀបចំឡើងនៅការិយាល័យអង្គការCTO។

**7.6. ពង្រឹងសមត្ថភាពអង្គភាព**

អង្គការកែប្រែសហគមន៍ បានបង់វិភាគទានសមាជិកភាពដល់អង្គការបណ្តាញCCC ដើម្បីជាការចូលរួមបដិភាគទ្រទ្រង់បណ្តាញថ្នាក់ជាតិសម្រាប់ជាបណ្តាញអង្គការសង្គមស៊ីវិល និងអត្ថប្រយោជន៍ផ្សេងៗទៀតដល់អង្គការ។ ក្រោយពីមានអនុសាសន៍ព្រមទាំងសកម្មភាពដែលអង្គការកែប្រែសហគមន៍ ត្រូវដោះស្រាយចាត់វិធានការ គណៈគ្រប់គ្រងបានចុះទៅកាន់ការិយាល័យឧត្តរមានជ័យ ដើម្បីធ្វើការប្រជុំពិភាក្សាដោះស្រាយនូវចំនុចអនុសាសន៍ ដែលរកឃើញក្នុងរបាយការណ៍ចុះត្រួតពិនិត្យប្រចាំឆ្នាំ អោយបានទាន់ពេលវេលា។ យើងក៏បានធ្វើការថតចំលងសំណុំឯកសារ នៃការបណ្តុះបណ្តាល និងផ្តល់ការដំឡើងកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុ Quickbook ដល់អង្គការដៃគូរទាំង៧ផ្សេងទៀត ទុកជាឯកសារតម្កល់ទុកតាមអង្គការនីមួយៗ។ បុគ្គលិកគម្រោង៣រូបបានចូលរួមសិក្ខាសាលាស្តីអំពី M&E រួមជាមួយនឹងអង្គការដៃគូរក្នុងក្របខ័ណ្ឌគម្រោង LRP ផ្សេងទៀតដែលរៀបចំឡើងដោយអាក់សិនអេដ នៅរាជធានីភ្នំពេញ ក្នុងគោលបំណងពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដានតាមស្ថាប័នអោយកាន់តែប្រសើរ និងដោះស្រាយកែលំអរចំនុចខ្វះខាតដែលមានជុំវិញបញ្ហាM&Eនេះ។ ម្យ៉ាងវិញទៀតដើម្បីអោយដៃគូរសហការពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍អ្នកទទួលផលបានយល់ដឹងពីចំណេះដឹង គោលនយោបាយនានាដែលគម្រោងមាន យើងបានថតចម្លងសំណៅឯកសារគោលនយោបាយដែលមានដូចជាគោលនយោបាយស្តីពីការបៀតបៀន កេងប្រវ័ញ្ច ជួញដូរ និងរំលោភស្រ្តីនិងកុមារ គោលនយោបាយគាំពារកុមារ ព្រមទាំងប្រព័ន្ធរាយការណ៍ចែកជូនតាមគ្រប់តំបន់គោលដៅ។

តាមរយៈគម្រោងកម្មវិធីសិទ្ធិនៅមូលដ្ឋាន (LRP) ក្នុងភាពជាដៃគូរជាមួយអង្គការអាក់សិនអេដកម្ពុជា (AAC) ដែលកំពុងអនុវត្តនៅខេត្តគោលដៅយុទ្ធសាស្រ្តគម្រោងនៃខេត្តឧត្តរមានជ័យ បានលើកផែនការសកម្មភាពក្នុងគោលបំណងជួយពង្រឹងសមត្ថភាពស្ថាប័ន និងបុគ្គលិក ដើម្បីអោយមានសមត្ថភាព ជួយជម្រុញការអនុវត្តគម្រោងបានជោគជ័យ និងជួយអោយស្ថាប័នកាន់តែមានសមត្ថភាពរឹងមាំជាទំនុកចិត្ត ដល់ដៃគូផ្តល់ជំនួយ និងប្រសិទ្ធភាពការងារខ្ពស់ដើម្បីបន្តនិរន្តភាពដោយខ្លួនឯងនៅពេលអនាគត់ ក៏ដូចជាគៀងគរដៃគូរ បន្ថែមក្នុងការពង្រីកសមត្ថភាព ជួយដល់សហគមន៍អោយបានកាន់តែច្រើន។ ការរកអ្នកជំនាញផ្នែករចនាគេហទំព័រអោយមកជួយក្នុយងគោលបំណង៖

- ដើម្បីដោះស្រាយបញ្ហាគេហទំព័រដែលបានខូចមិនដំណើរការ អោយដំណើរការឡើងវិញ
- ដើម្បីអោយមានគេហទំព័រផ្សព្វផ្សាយពីកេរ្តិ៍ឈ្មោះស្នាដៃនិងសមិទ្ធិផលអង្គការដល់សាធារណៈជន
- ដើម្បីកែលំអរចំនុចខ្វះចន្លោះនិងអភិវឌ្ឍសមត្ថភាពគេហទំព័រអោយស្របតាមបរិបទសម័យកាល
- ដើម្បីសិក្សាលទ្ធភាពកែសម្រួលគេហទំព័រអោយមានជា២ភាសាខ្មែរ អង់គ្លេស

ដើម្បីឆ្លើយតបទៅនឹងតម្រូវការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការផ្សព្វផ្សាយពីស្នាដៃនិងព័ត៌មានទៅដល់សាធារណៈជន ដៃគូរអភិវឌ្ឍ រដ្ឋាភិបាល និងម្ចាស់ជំនួយ តាមរយៈការប្រើប្រាស់គេហទំព័រអេឡិចត្រូនិច។ ដោយសារកត្តា ធនធានហិរញ្ញវត្ថុ និងធនធាន

មនុស្សនៅក្នុងស្ថាប័នមានកម្រិត យើងមិនអាចមានលទ្ធភាពជួលបុគ្គលិកពេញម៉ោង ផ្នែកព័ត៌មានវិទ្យា ដើម្បីទទួលខុសត្រូវផ្តាច់មុខទៅលើវិស័យហ្នឹងបាន ទើបធ្វើអោយការរៀបចំនិងការគ្រប់គ្រងលើ ផ្នែកហ្នឹងនៅមានការខ្វះខាតទន់ខ្សោយដែលត្រូវជួយអភិវឌ្ឍបន្ថែម។ គេហទំព័រអេឡិចត្រូនិចរបស់ស្ថាប័នធ្លាប់មាន ខាងអ្នកស្ម័គ្រចិត្តពីបរទេសមកជួយរៀបចំអោយបានដាក់ដំណើរការរួចហើយ ប៉ុន្តែដោយសារមិនមានអ្នកទទួលខុសត្រូវគ្រប់គ្រងថែទាំ តាមដានវាបានជិតដល់ក៏ដូចជា មិនមានអ្នកជំនាញអាចគ្រប់គ្រងច្បាស់លាស់ វាបានខូចលែងដំណើរការដោយមិនដឹងមូលហេតុ។ ដូច្នេះគម្រោងបានដាក់ផែនការដើម្បីស្វែងរកអ្នកជំនាញ ដើម្បីអោយមកជួយដោះស្រាយឡើងវិញ តាមរយៈការជួយពិនិត្យស្ថានភាពបញ្ហា និងផ្តល់យោបល់ក្នុងការដោះស្រាយបញ្ហា ដើម្បីអាចអោយគេហទំព័រនេះអាចដំណើរការដូចប្រក្រតីឡើងវិញបំពេញមុខងារជួយផ្សព្វផ្សាយដល់ស្ថាប័ន។

ជាតម្រូវការក្នុងការពង្រឹងសមត្ថភាពស្ថាប័ន ក្នុងការត្រួតពិនិត្យតាមដានការងារនៅសហគមន៍អោយកាន់តែ មានភាពងាយស្រួល លឿន រហ័ស ក៏ដូចជាការជួយសហគមន៍ក្នុងការលើកគម្រោងប្លង់អភិវឌ្ឍព្រៃសហគមន៍ ការត្រួតពិនិត្យតាមដានការវិវឌ្ឍគម្របព្រៃឈើដោយប្រើបច្ចេកវិទ្យាគ្រប់គ្រងភូមិសាស្ត្រសំដៅកាត់បន្ថយពេលវេលានិងការលំបាក យើងបានសម្រេចអោយបុគ្គលិកបានរៀនពីការប្រើប្រាស់មូលដ្ឋាននៃកម្មវិធីវិទ្យាសាស្ត្រគ្រប់គ្រងទិន្នន័យភូមិសាស្ត្រ ArcGIS/ArcGIS pro និង CarryMaps ហើយនឹងការទិញsofware license បំពាក់លើកុំព្យូទ័រដើម្បីជាប្រយោជន៍ប្រើប្រាស់ដែលនឹងសម្របសម្រួលបណ្តុះបណ្តាលដោយអ្នកជំនាញដែលមានបទពិសោធន៍សមត្ថភាពច្បាស់លាស់ក្នុងគោលបំណង៖

- ឆ្លើយតបទៅនឹងតម្រូវការការងារគ្រប់គ្រងក្នុងស្ថាប័ន
- ប្រើលើការត្រួតពិនិត្យតាមដានលើការងារនៅសហគមន៍អោយកាន់តែមានភាពងាយស្រួលរហ័ស
- ការជួយសហគមន៍ក្នុងការលើកគម្រោងប្លង់អភិវឌ្ឍព្រៃសហគមន៍ ការត្រួតពិនិត្យ និងការតាមដាន ការវិវឌ្ឍគម្របព្រៃឈើដោយប្រើបច្ចេកវិទ្យាគ្រប់គ្រងភូមិសាស្ត្រសំដៅកាត់បន្ថយពេលវេលានិងការលំបាក
- អោយបុគ្គលិកបានរៀនពីការប្រើប្រាស់មូលដ្ឋាននៃកម្មវិធីវិទ្យាសាស្ត្រគ្រប់គ្រងទិន្នន័យភូមិសាស្ត្រ ArcGIS/ArcGIS pro និង CarryMaps

**កម្មវិធីកុមារ**

គោលបំណងទី១៤៖ ១៤.ពង្រឹងដំណើរការគាំពារកុមារមានភាពប្រសើរឡើងជាងមុន

**លទ្ធផលរំពឹងទុកទី ១៤.១៖** ១៤.១. កុមារចំនួន១,២៥៧នាក់/កុមារី៦៩១នាក់ ស្ថិតនៅសង្កាត់សំរោង បន្សាយ រាក់ និងឃុំគោកខ្ពស់ អាចទទួលបានការគាំទ្រនិងអត្ថប្រយោជន៍ ពីកម្មវិធីអភិវឌ្ឍ សហគមន៍ តាមរយៈ ការគូរសារ កម្មវិធីសប្បាយៗ ក្លឹបកុមារ និងការលើក កំពស់សិទ្ធិក្នុងសាលារៀន។

| **សុចនករ** | **ផែនការ១ឆ្នាំ** | **លទ្ធផល១ឆ្នាំ** | **ពន្យល់ពីគម្លាត** |
|---|---|---|---|
| 14.1 ផ្ញើឯកសារ/Sending document | ១២លើក | ១៨លើក | តាមស្ថានភាពជាក់ស្តែង |
| 14.2. សិក្ខាសាលាកម្មវិធីកុមារ | ១លើក | ១លើក | ភាពចាំបាច់ដើម្បីណែនាំពីបច្ចុប្បន្នភាពពីមុខងារ និងកិច្ចការថ្មីៗមួយចំនួនដល់មន្ត្រីទទួលបន្ទុកកម្មវិធីកុមារ |
| 14.3. ទិញSmart Phone | ២គ្រឿង | 0គ្រឿង | មិនមានការណែនាំពីAACសម្រាប់ការបញ្ជាទិញថវិកាបានបង្វែយកទៅប្រើប្រាស់ក្នុងសកម្មភាពផ្សេង |

| | | | |
|---|---|---|---|
| 14.4. ប្រជុំគ្រូបង្គោល១ឆ្នាំ២ដង | ២ដង | ១ដង | មានការផ្តល់អនុសាសន៍ពីកញ្ញានីតា អោយធ្វើតែម្តងនៅខែ១០ ហើយថវិកាបង្វែរគាំទ្រការប្រមូលសារវិញ |
| 14.5. សម្ភារ:គូសារកុមារ | ២លើក | ១លើក | នៅឆមាសទី១យើងនៅសល់សម្ភារៈពីឆ្នាំ២០២១ ចឹងយើងទិញនៅខែ១០ម្តងទៀត |
| 14.6. ប្រមូលសារ១ឆ្នាំ២ដង | ១៣៥៨នាក់ | ៩៨៩នាក់ | កុមារធំ និងចំណាកស្រុកត្រូវកាត់ចេញពីបញ្ជីដើម យើងប្រមូលបានសុរប៩៨៩នាក់សម្រាប់កុមារចាស់ មិនទាន់បញ្ចូលថ្មី |
| 14.7. សរសេររបាយការណ៍អត្ថបទរឿងខ្លីៗ | ២ករណី | ២ករណី | កុមារគូសារ១ករណីគ្រូបង្គោល១ករណី |
| 14.8. សរសេររបាយការណ៍សំឡេងសហគមន៍ | ២ករណី | ២ករណី | យុវជន១កណី តំបន់ទេសចរធម្មជាតិ១ករណី |
| 14.9. កម្មវិធីសប្បាយៗតាមក្លឹប | ០ដង | ០ដង | មិនមានក្នុងផែនការ និងថវិកា |
| 14.10.ប្រមូលសារកុមារថ្មី និងប្រវត្តិរូបកុមារជំនួសកុមារចំណាកស្រុក | ១៥០នាក់ | ១៣៥នាក់ | នៅខ្វះ១៥នាក់ |
| 14.11.ព្រីនរូបថតកុមារគូរសារសម្រាប់ភ្ជាប់ប្រវត្តិរូប | ១២៥៨នាក់ | ៩៨៩នាក់ | បានតាមជាក់ស្តែង |
| 14.12.កញ្ចប់ថវិកាឧបត្ថម្ភបម្រុងទុកសម្រាប់ប្រើក្នុងគ្រាមានអាសន្នលើកុមារគូរសារក្នុងកម្មវិធីកុមារ | ០នាក់ | ០នាក់ | យោងលើស្ថានភាពជាក់ស្តែង មិនមានកុមារដែលជួបគ្រោះថ្នាក់ទេ |
| 14.13.បញ្រៀបគោលនយោបាយស្តីពីការការពារកុមារ ការបៀតបៀន ការកេងប្រវ័ញ្ច ការរំលោភបំពានផ្លូវភេទ | ២៥សាលា | ២៥សាលា | បញ្ចប់តាមផែនការ |
| 14.14.បញ្រ្ជៀបគោលនយោបាយកម្មវិធីកុមារដល់សហគមន៍និ | ២៥ភូមិ | ២៥ភូមិ | បញ្ចប់តាមផែនការ |

| | | | |
|---|---|---|---|
| ងកុមារ | | | |

14.1 ផ្ញើឯកសារ/Sending document

អង្គការកែប្រែសហគមន៍បានផ្ញើរសំណុំឯកសារ សារកុមារចេញចំនួន១៨ដង ទៅកាន់AAC ដែលសំណុំឯកសារដែលផ្ញើរទាំងអស់គឺសារកុមារដែលបានប្រមូលរួច។

**14.2. សិក្ខាសាលាកម្មវិធីកុមារ**

កម្មវិសិក្ខាសាលាកម្មវិធីកុមារមានបុគ្គលិកCTO ចំនួន៣រូបទៅចូលរួម ដោយសារបុគ្គលិកទទួលបន្ទុកកុមារមានផ្ទៃពោះជិតឆ្លងទន្លេមិនអាចទៅបាន ដូចនេះCTOបានបញ្ជូនមន្រ្តីហិរញ្ញវត្ថុ២រូប និងបុគ្គលិកជំនួយការកុមារ១រូបទៅចូលរួមសិក្ខាសាលានេះ។ អង្គការអាក់សិនអេត រៀបចំសិក្ខាសាលាកម្មវិធីកុមារប្រចាំឆ្នាំរយៈពេលបីថ្ងៃ ដែលប្រព្រឹត្តទៅនៅថ្ងៃទី ២០-២១-២២ ខែធ្នូ ឆ្នាំ២០២២ នៅរាជធានីភ្នំពេញ។ សិក្ខាសាលានេះមានគោលបំណង ដើម្បីពង្រឹងសមត្ថភាពបន្ថែមដល់មន្រ្តីកម្មវិធីកុមារ និងមន្រ្តីពាក់ព័ន្ធរបស់អង្គការដៃគូ ទៅលើការសរសេរនិងប្រមូលរបាយការណ៍ ការថតរូបដាក់របាយការណ៍និងករណីសិក្សា និងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងកម្មវិធីកុមារថ្មីឈ្មោះថាសហគមន៍ SAHAKOM។

14.3. ទិញSmart Phone

សកម្មភាពនេះមិនបានអនុវត្ត ដោយមិនមានការបញ្ជាក់ពីការអនុញ្ញាតិពីខាងAAC យ៉ាងណាក៏ដោយAAC បានណែនាំអោយបង្វែថវិកានេះយកទៅប្រើប្រាស់លើសកម្មភាពសិក្ខាសាលាប្រចាំឆ្នាំកម្មវិធីកុមារនៅខែធ្នូ២០២២។

**14.4. ប្រជុំគ្រូបង្គោល១ឆ្នាំ២ដង**

មានការផ្តល់អនុសាសន៍ពីខាងភាគីអាក់សិនអេដ (កញ្ញានីតា) អោយធ្វើតែម្តងនៅខែតុលា ២០២២ ហើយថវិកានៅសល់បង្វែរគាំទ្រការប្រមូលសារ និងប្រវត្តិរូបកុមារថ្មីចំនួន១៥០នាក់វិញ។

**14.5. សម្ភារៈគូសារកុមារ**

នៅឆមាសទី១យើងមាននៅសល់សម្ភារៈពីឆ្នាំ២០២១ ចឹងយើងត្រូវការទិញនៅខែតុលា២០២២តែម្តងដែលមានសម្ភារៈដូចខាងក្រោម៖

- ដែកខួង Master Art 112=50កំប៉ុង
- គូល័រជាត់ពណ៌ឈើ Giraffe (1ប្រអប់=12ដើម)=250 ប្រអប់
- ខ្មៅដៃ Giraffe(1ប្រអប់=12 ដើម)=400កំប៉ុង
- ជ័រលុប Giraffe= 68កំប៉ុង
- ជាស់ A4 (Double A 80g)=4កេះ

**14.6. ប្រមូលសារ១ឆ្នាំ២ម្តង**

ប្រមូលសារកុមារបាន ៣៤ភូមិ ក្នុង ២ឃុំ ៣សង្កាត់ ២ស្រុក ១ក្រុង លទ្ធផលទទួលបាន៖

- បានប្រមូលសារកុមារបានចំនួន១១៣៩សារកុមារ
- បានផ្ញើរសារកុមារ ទៅអាក់សិនអេត ចំនួន១១៣៩នាក់
- កុមារបានយល់ពីការសារៈសំខាន់នៃការគូសារកុមារ ពីអនាម័យ ពីការការពាកូវិត១៩ និងយល់ដឹងពីការផាត់រូបនិងគូរគំនូរយ៉ាងមានរបៀប

បញ្ហាដែលរារាំងមិនបានប្រមូលទាន់គ្រប់ចំនួនតាមពេលវេលាព្រោះ៖

- កុមាររៀបការ
- កុមារធំមិនចូលរួម

- កុមារចំណាកស្រុក
- កុមារទៅសម្រាកនៅស្រែចំការ
- កុមារថ្នាក់ធំឡើងមករៀន នៅវិទ្យាល័យ
- កុមារស្វែរកថវិការដោយខ្លួនឯង

បុគ្គលិកកម្មវិធីកុមារបានចុះធ្វើការប្រមូលសារចំនួន១៥វគ្គដែលមានលទ្ធផលដូចខាងក្រោម

| កាលបរិច្ឆេទ | សរុប | ស្រី | បរិយាយតាមភូមិ |
|---|---|---|---|
| 04-10/05/22 | ២២៦ | ១១៨ | -គោកសង្កែ ២៧/១២ -គោកសង្កែ ៣៣/១៣ -អំពិល ៣៧/២៣ -អំពិល ៣៦/១៩ -ត្នោត ៣០/១៧ -ត្នោត ២៩/១៥ -ពោធិវង្ស ៣៤/១៩ |
| 16-22/05/22 | 280 | 156 | -អំពិល ២៥/១១ -ត្រពាំងវែង ៣២/២០ -បាក់នឹម ៤៣/៣៤ -បាក់នឹម ៤៣/២៣ -បាក់នឹម ៣៩/១៩ -ត្រពាំងវែង ២៤/១១ -តាម៉ាន ៤០/២០ -តាម៉ាន ៣៤/១៨ |
| 25-31/05/22 | 164 | 101 | -សំបួរមាស២៨/១៩ -គោកច្រេស ២៤/១៦ -ឈើស្លាប់ ៣០/១៥ -ឈើស្លាប់២៣/១៤ -គាប៣០/១៦ -ប្រិយ៍ ២៩/២១ |
| 07-13/06/22 | 224 | 133 | -តាប៉ែន ៤៦/២៦ -តាប៉ែន ៤១/២៣ -ខ្ញុំ ៤៥/២១ -ខ្ញុំ ៤៦/១៨ -ខ្ញុំ ១៤/៨<br>ស្រះកែវ ៤៤/១៧ -ស្រះកែវ ៣២/២០ |
| 15-19/06/22 | 96 | 47 | បន្សាយរាក់៤២នាក់ គោកខ្ពស់៣៩នាក់ អូឫស្សី១៥នាក់ |
| 21-25/06/22 | 131 | 70 | -អូរឫស្សី ២០/១៣ -បន្សាយរាក់ ២៧/១៤-បន្សារាក់ ២៦/១៤ -គោកខ្ពស់ ៤១/២១-គោកខ្ពស់ ១៧/៨ |
| 27-29/06/22 | 100 | 59 | បុស្សធំ៦១នាក់ មនោរម្យមួយ ៣៩នាក់ |
| 14-22/10/22 | 203 | 108 | ឈើស្លាប់៤៥នាក់ ព្រៃទទឹង២២នាក់ ប្រិយ២៩នាក់ គោកសង្កែ៥០នាក់ ស្រះកែវ៥៧ |
| 01-11/11/22 | 178 | 99 | តាប៉ែន៥៣នាក់ ពោធិវង្ស៣៥នាក់ គោកច្រេស២៥នាក់ ឆ្អើប២៥នាក់ អូរកន្សែង២០នាក់ អូរឫស្សី២០នាក់ |
| 14-19/11/22 | 182 | 101 | បន្ទាយជ័រ៥៨នាក់ បាក់នឹម១២៥នាក់ ពុរ៣០នាក់ |
| 21-28/11/22 | 230 | 125 | តាម៉ាន៨០នាក់ ខ្ញុំ១០០នាក់ គោកខ្ពស់៥០នាក់ |
| 01-10/12/22 | 260 | 170 | អំពិល៨៥នាក់ ឈើស្លាប់៦០នាក់ គោកខ្ពស់៥០នាក់ បន្ទាយជ័រ៦៥នាក់ |
| 12-17/12/22 | 190 | 115 | ខ្ញុំ១២០នាក់ អូរឫស្សី៣០នាក់ ពោធិវង្ស ៤០នាក់ |
| 19-24/12/22 | 190 | 111 | អំពិល១១០នាក់ បន្សាយរាក់៦០នាក់ បាក់នឹម២០នាក់ |
| 26-30/12/22 | 280 | 161 | ស្រះកែវ គោកសង្កែ អំពិល បន្ទាយជ័រ តាប៉ែន ៧០នាក់ គោកខ្ពស់ ប្រិយ គាប ឈើស្លាប់ អូរទង ៦០នាក់ ដូនកែន ឈូក ពុរ អូរកន្សែង អូរឫស្សី គោកច្រេច ៤០នាក់ រំដួលវាសនា បន្សាយរាក់ ពោធិវង្ស |

| | | | |
|---|---|---|---|
| | | | សំបូរមាស ៥០នាក់ ត្រពាំងវែង ខ្ទុំ តាម៉ាន ថ្នល់បត់ ថ្មី ៦០នាក់ |

**14.7. សរសេររបាយការណ៍អត្ថបទរឿងខ្លីៗ**

អង្គការកែប្រែសហគមន៍បានចាត់ចែងសរសេរអត្ថបទរឿងបាន២រឿងខ្លីៗ ទៅលើកុមារគូរសារ១រឿង និងទៅលើគ្រូបង្គោលតាមភូមិ១រឿងដើម្បីផ្ញើទៅអាក់សិនអេដ។

**14.8. សរសេររបាយការណ៍សំឡេងសហគមន៍**

មានចំនួន២ករណី ទី១អំពីយុវជន និងទី២អំពីសហគមន៍ទេចរធម្មជាតិ

**14.9. កម្មវិធីសប្បាយៗតាមក្លឹប(បញ្ហាបកម្មវិធីកុមារ)**

មិនមានក្នុងផែនការ ហើយក៏មិនមានថវិកគ្រោងដូចគ្នា

**14.10.ប្រមូលសារកុមារថ្មី និងប្រវត្តរូបកុមារជំនួសកុមារចំណាកស្រុក**

ដោយមានការជូនដំណឹងពីក្រុមការងារកម្មវិធីកុមាររបស់អង្គការអាក់សិនអេដ យើងបានសហការជាមួយអាជ្ញធរភូមិជនបង្គោល និងអាណាព្យាបាលកុមារធ្វើការចុះប្រមូលសាកុមារថ្មី និងប្រវត្តិរូបកុមារជំនួសកុមារចំណាកស្រុកបានសរុប១៣៥នាក់ស្រី៧២នាក់ និងបានធ្វើការណែនាំពីអនាម័យ និងការការពារពីជំងឺកូវីដ១៩។

**14.11.ព្រីនរូបថតកុមារគូរសារសម្រាប់ភ្ជាប់ប្រវត្តិរូប**

ព្រីនបានគ្រប់ចំនួនតាមផែនការ

**14.12.កញ្ចប់ថវិកាឧបត្ថម្ភបម្រុងទុកសម្រាប់ប្រើក្នុងគ្រាមានអាសន្នលើកុមារគូរសារក្នុងកម្មវិធីកុមារ**

ឆ្នាំ២០២២នេះយើងមានក្តីសោមនស្សរីករាយណាស់ជាសំណាងល្អព្រោះមិនមានករណីកុមាររងគ្រោះទេ។

**14.13.បញ្រៀបគោលនយោបាយស្តីពីការការពារកុមារ ការបៀតបៀន ការកេងប្រវ័ញ្ច ការរំលោភបំពានផ្លូវភេទ**

បានចុះអប់រំផ្សព្វផ្សាយតាមសាលារៀនគោលដៅគម្រោងទាំង២៥ ចំនួន១ដងក្នុង១សាលា អំពីគោលនយោ បាយស្តីពីការការពារកុមារ ការបៀតបៀន ការកេងប្រវ័ញ្ច ការរំលោភបំពានផ្លូវភេទ ដែលមានអ្នកចូលរួមសរុប១១៥៨នាក់ ស្រី៥៦៩នាក់ ដោយប្រើវិធីសាស្រ្ត

- មានចែកមេរៀន
- ពន្យល់លើមេរៀន
- សំណួរ ឆ្លើយ និង រំលឹក ការចងចាំ

ជាលទ្ធផលសម្រេចបានក្រោយពីការផ្សព្វផ្សាយ

•ប្អូនសិស្សានុសិស្សបានទទួលចំណេះដឹងបន្ថែមនិងអាចយកចំណេះដឹងនេះទៅធ្វើការផ្សព្វផ្សាយបន្តដល់ប្អូនៗសិស្សានុសិស្សដែលមិនបានទទួលការផ្សព្វផ្សាយផ្ទាល់ក៏បានទទួលចំណេះដឹងដូចគ្នា

• ប្អូនសិស្សានុសិស្សបានយល់ដឹងក្រុមដែលងាយរងគ្រោះជាងគេលើការ បៀតបៀន កេងប្រវ័ញ្ច និងការរំលោភ។ ប្អូនសិស្សានុសិស្សបានយល់ដឹង អ្វីទៅហៅថាការបៀតបៀន ?

**14.14.បញ្ជ្រៀបគោលនយោបាយកម្មវិធីកុមារដល់សហគមន៍និងកុមារ**

ធ្វើការចុះបញ្ជ្រៀបអំពីកម្មវិធីកុមារដល់សហគមន៍ចំនួន២៥ភូមិគោលដៅដែលមានអ្នកចូលរួមសរុប១១៧០នាក់ស្រី៨៨៧។

**ឧបសគ្គ:**

| |
|---|
| • ការសម្របសម្រួលការងាររវាងគណៈគ្រប់គ្រង ទៅកាន់ការិយាល័យសាខាពីចំងាយមានការលំបាកខ្លះទៅលើការអនុវត្តតួនាទីមុខងារ តាមក្រិតក្រម ឬនិតិវិធីគោលការណ៍ដែលមាន។ |

- បុគ្គលិកកម្មវិធីកុមារមិនសូវមានជំនាញនិងទេពកោសល្យលើការច្នៃប្រឌិតសារ ធ្វើអោយគុណភាពសារកុមារមិនសូវទាក់ទាញ។
- បុគ្គលិក ភាគច្រើនជាស្រ្តី ម្យ៉ាងពិបាកស្វែងរកព្រោះប្រាក់ខែដែលមាននៅកម្រិតទាបដែលអាចទាក់ទាញបុរសអោយដាក់ពាក្យ ធ្វើអោយមានការបារម្ភពីសុវត្ថិភាពបុគ្គលិកពេលចុះបំពេញការងារតាមភូមិដាច់ស្រយាល។
- ការជ្រើសរើសក្រុមប្រឹក្សាភិបាលស្ម័គ្រចិត្តមិនមានអ្នកធ្វើ នាំអោយខ្វះកូរ៉ុមក្រុមប្រឹក្សាភិបាល ហើយមិនអាចធ្វើបច្ចុប្បន្នភាពលក្ខន្តិកៈអង្គការតាមច្បាប់កំណត់។
- កុំព្យូទ័របុគ្គលិកភាគច្រើនចាស់ៗ សមត្ថភាពទាប ហើយLicense Window crack ធ្វើអោយល្បឿនការងារមានការយឺតយ៉ាវ ដោយសារការរំខាន License និងល្បឿនយឺតព្រោះភាគច្រើនStorageជា HDD មិនមែនSSD។

## IV. របាយការណ៍ហិរញ្ញវត្ថុ

| ល.រ | បរិយាយ | ផែនការ | ចំណាយ | សមតុល្យ | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | *រដ្ឋបាល* | *14,660.00* | *14,550.15* | *109.85* | *ចំនាយរដ្ឋបាលនៅសល់ដោយសារខ្ទង់*<br><br>*ការចំណាយទៅលើការធ្វើឯការ*<br>*នៅសល់ដោយឯកសារជារៀយ*<br>*ធ្វើតាមនាយកចុះមកធ្វើការនៅឧត្តរមានជ័យ*<br><br>*Electricity and water cost៖*<br>*ដោយសារការប្រើប្រាស់មិនស្ថិតស្ថេរ*<br><br>*Bank charge ថ្លៃសេវាបច្ចុប្បន្នខាងធនាគារបានចុះថ្លៃ*<br>*ហើយនឹងមិនគិតថ្លៃដូចមុនរាល់ពេលប្រតិបត្តិការ* |
| ២ | *កម្មវិធី* | *44,484.00* | *42,326.63* | *2,157.37* | *ចំណាយកម្មវិធីនៅសល់ព្រោះខ្ទង់ថវិកា*<br><br>*ត្រៀមបង្កា និងឆ្លើយតបគ្រោះ*<br>*មហន្តរាយ៖មិនមានគ្រោះមហន្តរាយធ្ងន់ធ្ងរកើតឡើង*<br>*ហើយរហូតមកដល់ខែ១២*<br>*ហើយយើងបានពិភាក្សាពិគ្រោះយោបល់ដើម្បីស្នើសុំរុះរើយក*<br>*ទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងជាមួយខាងអាក់សិនអេដ*<br>*(លោកស្រីចន្ទូ) គាត់ផ្តល់យោបល់អោយរក្សាទុក*<br>*ទើបយើងមិនបានលើកចំណាយ។*<br><br>*រៀបចំ និងត្រួតពិនិត្យផែនការឆ្នាំ២០២២៖យើងគ្រោងធ្វើនៅ*<br>*ចុងខែវិច្ឆិកា ប៉ុន្តែជាក់ស្តែង ការរៀបចំផែនការ២០២៣*<br>*ខាងអាក់សិនអេដបានរៀបចំកៀកថ្ងៃ មិនអាចរៀបចំ* |

| | | | | | |
|---|---|---|---|---|---|
| | | | | | *ហើយយើងបានត្រឹមតែសម្របសម្រួល ទំនាក់ទំនងពិគ្រោះយោបល់តាមទូរស័ព្ទជំនួសអោយការធ្វើផ្ទាល់ដែលបានគ្រោង*<br><br>*ពង្រឹងសមត្ថភាពអង្គភាព បុគ្គលិកមមាញឹកការងារស្ទួលពេលមិនអាចលៃពេលដើម្បីទៅធ្វើការបណ្តុះបណ្តាលបានលើជំនាញបង្វឹកកុមារក្នុងការថ្លៃប្រឌិតសារកុមារ។ ហើយខ្ទង់សម្រាប់ទំនាក់ទំនងធ្វើបច្ចុប្បន្នភាពលក្ខន្តិកៈអង្គការអោយស្របតាមច្បាប់NGOs មិនទាន់អាចធ្វើបានដោយសារ ខ្វះគូរុមក្រុមប្រឹក្សាភិបាល ហើយខាងក្រសួងតម្រូវអោយតម្កល់ប្រវត្តិរូប និងអត្តសញ្ញាណប័ណ្ណធ្វើអោយពិបាករកអ្នកស្ម័គ្រចិត្តបង្គ្រប់គូរុមក្រុមប្រឹក្សាភិបាល ហើយក្រុមប្រឹក្សាភិបាលមុនស្នើអោយជ្រើសថ្មីព្រោះពួកគាត់ចាកចេញពីស្រុកខ្មែរទៅប្រទេសកំណើតគាត់វិញពិបាកក្នុងការបំពេញតួនាទីជូន ហេតុនដូចនេះទើបយើងត្រូវសល់លុយខ្ទង់នេះមួយផ្នែក។*<br><br>*Smart Phone សម្រាប់កម្មវិធីកុមារៈ មិនទាន់បានទិញដោយសាររងចាំការសម្រេចពី អាសិនអេត*<br><br>*កញ្ចប់ថវិកាឧបត្ថម្ភបម្រុងទុកសម្រាប់ប្រើក្នុងគ្រាមានអាសន្នលើកុមារគួរសារក្នុង កម្មវិធីកុមារ ៖មិនមានកុមារមណភាព ហើយរហូតដល់ខែ១២ យើងពិភាក្សាជាមួយខាងអាក់សិនអេដ ដើម្បីស្នើប្រើប្រាស់ តែខាងអាក់សិនអេដ អោយរក្សាទុក ក្រែងមានក្មេងមានបញ្ហាមិនមានថវិកាប្រើប្រាស់* |
| | សរុប | 59,144.00 | 56,876.78 | 2,267.22 | |

V. **<u>ផែនការទិសដៅការងារបន្ត</u>**

<u>ខេត្តសៀមរាប</u>

កំពុងស្វែងរកម្ចាស់មូលនិធិគាំទ្រសម្រាប់ខេត្តសៀមរាប

ខេត្តឧត្តរមានជ័យ

**លទ្ធផលរំពឹងទុកទី៣.៣៖** សមាជិកសហគមន៍ចំនួន០៣ (សហគមន៍ព្រៃឈើរំដួលវាសនា សហគមន៍ព្រៃឈើ សំរែកព្រៃស្រស់ និងសហគមន៍ព្រៃឈើវត្តនរុក្ខា និងបណ្តាញសហគមន៍ព្រៃឈើ) យ៉ាងតិច៧០% ក្នុងចំណោម សមាជិកសហគមន៍ព្រៃឈើសរុប ៤២៦នាក់ និងស្ត្រី១៨៥នាក់ និងបណ្តាញសហគមន៍ចំនួន១២នាក់ មានស្ត្រីម្នាក់ បានយល់ច្បាស់អំពីការបង្កើតសហគមន៍ព្រៃឈើ អត្ថប្រយោជន៍នៃការបង្កើតសហគមន៍ព្រៃឈើ ព្រំប្រទល់ព្រៃសហគមន៍ ព្រមទាំងបានចូលរួមក្នុងសកម្មភាពការពារ និងគ្រប់គ្រងព្រៃសហគមន៍របស់ពួកគាត់។

៣.៣.១-បោះឆ្នោតជ្រើសរើស និងកែសម្រួលគណៈកម្មការសហគមន៍ព្រៃឈើចំនួន៣
៣.៣.២-ធ្វើបច្ចុប្បន្នភាពគណកម្មការ និងសមា ជិកសហគមន៍ឡើងវិញ នូវសហគមន៍ព្រៃឈើចំនួន៣
៣.៣.៣-ប្រជុំទៀងទាត់របស់សមាជិកបណ្តាញសហគមន៍ព្រៃឈើខេត្តឧត្តរមានជ័យ ៣ដងក្នុងមួយឆ្នាំ
៣.៣.៤-គាំទ្រ និងការចូលប្រជុំ សិក្ខាសាលា និងសកម្មភាពអន្តរាគមន៍ និងដំណោះស្រាយជាមួយនឹង សហគមន៍ដៃគូ អង្គការ ស្ថាប័ន ឬនិងអាជ្ញាធរពាក់ព័ន្ធនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ។
៣.៣.៥-គាំទ្រលើផែនការសកម្មភាពអាទិភាព របស់សហគមន៍ព្រៃឈើ និងបណ្តាញសហគមន៍ព្រៃឈើផ្អែកតាមសំណើរ និងលទ្ធភាពឆ្លើយតបជាក់ស្តែង
៣.៣.៦-ចូលរួមនិងគាំទ្រក្នុងការបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិភ្នំដងរែកសម្រែកព្រៃស្រស់
៣.៣.៧-គាំទ្រគណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍ឃុំ-សង្កាត់ និងផែនការវិនិយោគឃុំ-សង្កាត់ប្រចាំឆ្នាំ

**លទ្ធផលរំពឹងទុកទី៤.១៖** ផែនការត្រៀមបម្រុង ត្រូវបានអនុវត្ត និងឆ្លើយតបគ្រោះមហន្តរាយខេត្តឧត្តរមានជ័យ

៤.១-សកម្មកភាពការត្រៀមបម្រុងសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ ឬ ឆ្លើយតបគ្រោះមហន្តរាយនៅខេត្តឧត្តរ មានជ័យ

**លទ្ធផលរំពឹងទុកទី៖ ៧.១-បុគ្គលិកអង្គការកែប្រែសហគមន៍ចំនួន៦នាក់/ស្រី៤នាក់ ទទួលបានចំណេះដឹងថ្មីៗតាមរយៈ ការចូលរួមសិក្ខាសាលា ការប្រជុំ ពីបណ្តាញ អង្គការដៃគូរនានាទាំងក្នុងខេត្ត និងក្រៅខេត្ត។**

៧.១-សិក្ខាសាលាភាពជាដៃគូ និងរៀបចំផែនការការយុទ្ធសាស្ត្រជាមួយ AAC
៧.២-វេទិកានាយក១ដងក្នុង១ឆ្នាំ
៧.៣=ត្រួតពិនិត្យនិងឆ្លុះបញ្ជាំងការអនុវត្តសកម្មភាពប្រចាំឆមាស (comprehensive monitoring)
៧.៤-ការចុះត្រួតពិនិត្យផ្ទៃក្នុង និងការជួយគាំទ្រពីការិយាល័យសៀមរាប
៧.៥-ពង្រឹងសមត្ថភាពអង្គភាព

**លទ្ធផលរំពឹងទុកទី ១៤៖ កុមារចំនួន ១,០៦៩នាក់/កុមារី៥៩១នាក់ ស្ថិតនៅសង្កាត់ សំរោង បន្សាយរាក់ និងឃុំគោកខ្ពស់អាចទទួលបានការគាំទ្រនិងអត្ថប្រយោជន៍ពីកម្មវិធីអភិវឌ្ឍសហគមន៍ តាមរយៈ ការគូរសារ កម្មវិធី សប្បាយៗ ក្លឹបកុមារ និងការលើក កំពស់សិទ្ធិក្នុងសាលារៀន។**

១៤.១-ផ្ញើឯកសារកម្មវិធីកុមារ/Sending CSP document
១៤.២-សិក្ខាសាលាកម្មវិធីកុមារ (Q3)
១៤.៤-ប្រជុំជាមួយគ្រូបង្គោល១ឆ្នាំ២ដង
១៤.៥-ទិញសម្ភារ:គូសារកុមារ
១៤.៦-ប្រមូលសារ១ឆ្នាំ២ដង ប្រមូលលិខិតឆ្លើយឆ្លង
១៤.៧-ប្រមូលអត្ថបទរឿងខ្លីៗ និងករណីសិក្សា
១៤.៩-កម្មវិធីសប្បាយៗ ឬ កម្មវិធីអប់រំផ្សេងៗ (ប្រចាំត្រីមាស ឬឆមាស)

១៤.១១-ផ្តិតរូបកុមារអ៊ីតាលី
១៤.១២-ការគាំទ្រថវិកាបម្រុងទុកសម្រាប់ប្រើក្នុងគ្រាមានអាសន្នលើកុមារគូរសារកម្មវិធីកុមារ (តាមគោលការណែនាំស្តីពីការគាំទ្រមរណភាពកុមារគូរសារ)
១៤.១៤-បញ្ច្រាបកម្មវិធីកុមារទៅសហគមន៍ (រៀងរាល់ត្រីមាស)
១៤.១៦-សិក្ខាសាលារំលឹកឡើងវិញកម្មវិធីកុមារ (Q4)

សៀមរាបថ្ងៃទី............ខែ..................... ឆ្នាំ២០២២
រៀបចំរបាយការណ៍ដោយ
**នាយកប្រតិបត្តិ**

បានឃើញនិងពិនិត្យ
**ប្រធានក្រុមប្រឹក្សាភិបាល**

.............................

..................................

រូបភាពសកម្មភាពគម្រោង






សកម្មភាពគណៈកម្មការសហគមន៍ចុះល្បាតព្រៃនិងទប់ស្កាត់បទល្មើសព្រៃឈើក្រោមការគាំទ្រថវិកាពីគម្រោង





បុគ្គលិកគម្រោងចុះសម្របសម្រួលប្រជុំពង្រឹងការគ្រប់គ្រង ដោះស្រាយបញ្ហា តាមសហគមន៍ព្រៃឈើទាំង១១ក្នុងខេត្ត






បុគ្គលិកគម្រោងចុះផ្សព្វផ្សាយពីគោលនយោបាយស្តីពីការបៀតបៀន ការរំលោភបំពាន ស្ត្រីកុមារ និកម្មវិធីកុមារនៅភូមិគោលដៅ៣៤ភូមិ២៥សាលា






ផ្តល់អំពូលសូឡាបំពាក់តាមខ្លោងទ្វារសាលា៦ ក្លឹបកុមារ២ និងបណ្ណាល័យ១ និងសម្របសម្រួលបោះឆ្នោតគណៈកម្មការសហគមន៍ព្រៃឈើ





ទិដ្ឋភាពឡដុតសម្រាមដែលគម្រោងគាំទ្រ និងសកម្មភាពដាំដំណាំបង្គាតាមសាលាសម្រាប់ការគាំទ្រកម្មវិធីបំណិជីវិតតាមសាលា